**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal De Droit Et Des Sciences Economiques

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក.ទេព ស្រីណាក់**

**ក.យន់ តារាច័ន្ទ**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **យន់ តារាច័ន្ទ** និងនាងខ្ញុំ **ទេព ស្រីណាក់** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសម្រេចនូវកម្រងសារណានេះឡើងៈ

សូមគោរពលំឱនកាយវាចាចិត្តសម្ដែងនូវមហាកតញ្ញូធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ លោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងផ្ដល់ដំបូន្មាន ផ្គត់ផ្គង់សព្វគ្រប់យ៉ាងទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ទាំងបញ្ញាស្មារតីក៏ដូចជាផ្នែកសម្ភារៈ តាំងពីយើងខ្ញុំបានចាប់កំណើតមករហូតដល់ធំដឹងក្ដីពេញរូបពេញរាង ដោយមិនខ្លាចហត់នឿយ ដែលលោកបាននឹងកំពុងខិតខំសព្វគ្រប់បែបយ៉ាង ដើម្បីឱ្យកូនបានសិក្សារៀនសូត្រតាំងពីថ្នាក់បឋមសិក្សារហូតដល់សព្វថ្ងៃ។ សេចក្ដីដឹងគុណទាំងអស់នេះ ពិតជាធំធេងពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតយើងខ្ញុំទាំងពីរ។

យើងខ្ញុំសូមថ្លែងអំណរគុណឯកឧត្ដមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជាមួយនិងកម្លាំងចិត្តកម្លាំងកាយក្នុងការបង្រៀន ផ្ដល់ចំណេះដឹង ការអប់រំ និងសីលធម៌ដល់យើងខ្ញុំទាំងពីរក្នុងរយៈពេល ៤ឆ្នាំនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណលោកសាស្ត្រាចារ្យ **ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំទាំងពីរ ដោយលោកសាស្ត្រាចារ្យបានចំណាយទាំងពេលវេលា និងកម្លាំង ក្នុងការផ្ដល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំរហូតមកដល់ការបញ្ចប់នៃការស្រាវជ្រាវមួយនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណរៀមច្បង និងមិត្តរួមជំនាន់ទាំងអស់ ដែលបានលើកទឹកចិត្តគាំទ្រ ផ្ដល់ជាយោបល់ គំនិត និងបទពិសោធន៍ល្អៗ ដែលបានជម្រុញយើងខ្ញុំឱ្យកាន់តែមានទឹកចិត្តក្នុងការសម្រេចនូវសារណានេះ ដើម្បីទុកជាឯកសារក្នុងការសិក្សាស្រាវជ្រាវផ្សេងៗ ជូនដល់មិត្តនិស្សិត និងប្អូនៗជំនាន់ក្រោយៗបានសិក្សាបន្ថែមកាន់តែស៊ីជម្រៅចំពោះប្រធានបទនេះ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរសូមធ្វើការអនុញ្ញាតគោរពបន្ទន់កាយសូមប្រសិទ្ធពរជ័យមង្គលជូនដល់លោកអ្នកមានគុណ លោកលោកស្រីសាស្ត្រាចារ្យទាំងអស់ សូមជួបប្រទះតែសេចក្ដីសុខ សុខភាពមាំមួន សុវត្ថិភាព និងប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសម្រេចបាននូវ ពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមក និងបានសិក្សាទៅលើជំនាញផ្នែកជាច្រើននៃនីតិឯកជន ព្រមទាំងផ្នែកនីតិសាធារណៈ យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនទៅលើមុខវិជ្ជានីមួយៗ ក្រោយមកការយកចិត្តទុកដាក់យ៉ាងខ្ពង់ខ្ពស់ពីសំណាក់សាស្ត្រាចារ្យទាំងអស់ដែលគាត់បានបង្ហាត់បង្រៀនយើងខ្ញុំពីដំណើរដើមទង ក៏ដូចជាលំហូរនៃនីតិវិធីមួយដែលកើតមានឡើង ជាពិសេសការអនុវត្តប្រកបដោយគុណធម៌ និងវិជ្ជាជីវៈថែមទៀតផង។ ដោយសារការខិតខំបង្ហាត់បង្រៀន និងការជួយជ្រោមជ្រែងអស់កម្លាំងកាយចិត្តពីសំណាក់សាស្ត្រចារ្យធ្វើឱ្យយើងខ្ញុំអាចឈានដល់ការចងក្រងនូវការបញ្ចប់សារណាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះឡើង។

ក្រោមការបង្ហាត់បង្រៀនពីសំណាក់លោកសាស្ត្រាចារ្យ ទើបញ៉ាំងឱ្យយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដែលទាក់ទងនឹងផ្នែកនីតិឯកជនដែលមានចំណងជើងថា៖ "**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**"។ មូលហេតុដែលយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទនេះឡើងគឺចង់ឱ្យបុគ្គលគ្រប់រូបដែលបានអាន យល់ច្បាស់អំពីអ្វីទៅជាលំហូរនៃនីតិវិធីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ពីព្រោះនាពេលបច្ចុប្បន្នមនុស្សជាច្រើនសុទ្ធសឹងតែមិនយល់ច្បាស់ទាក់ទងទៅនឹង ចំណងប្រព័ន្ធទ្រព្យសម្បត្តិដោយគាត់បានធ្វើការរំលងទៅនឹងនីតិវិធីនេះ ដោយពុំបានដឹងអំពីនីតិវិធីក៏ដូចជាអត្ថប្រយោជន៍ដែលទទួលបាន ការតតាំងជាមួយនឹងតតិយជន និងជាពិសេសការពារនៅពេលផលអវិជ្ជមានកើតមានឡើងនាពេលអនាគត។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សារណាមួយនេះដែលបានចងក្រងនេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវដល់ប្អូនៗជំនាន់ក្រោយក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានបំណងស្វែងសិក្សាបន្ថែមទាក់ទងនឹង លំហូរ ក៏ដូចជាប្រភេទ និងនីតិវិធីនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានកំណត់នៅក្នុងប្រកាសលេខ៨១នៃនីតិវិធីកិច្ចសន្យា និងក៏ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ចំពោះឯកសារនេះផងដែរ នឹងត្រូវបានរក្សាទុកជាស្នាដៃដល់អ្នកសិក្សាជំនាន់ក្រោយដែលបំណងក្នុងការសិក្សាស្វែងយល់បន្ថែមឱ្យកាន់តែស៊ីជម្រៅ ដើម្បីជាគន្លឹះក្នុងការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមទាក់ទងនឹងប្រធានបទនេះ។

ជាចុងក្រោយយើងខ្ញុំក៏សូមខន្តីអភ័យទោសផងដែរ ប្រសិនបើមានការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំមានចំណុចខ្វះខាតណាមួយទៅនឹងពាក្យពេចន៍មួយចំនួនៗ ខ្លឹមសារ ឬអត្ថន័យដែលកើតមាននៅក្នុងឯកសារចងក្រងនេះ ដោយអចេតនាហើយយើងខ្ញុំនឹងស្វាគមន៍ជានិច្ច ជាមួយការរិះគន់ផ្សេងៗ ដើម្បីស្ថាបនាឱ្យកាន់តែប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយកិច្ចសន្យា**

**ផ្នែកទី១ ទម្រង់នៃប្រព័ន្ធទ្រព្យសម្បត្តិ** ........................................ ៤

**កថាខណ្ឌទី១ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក** ........................................ ៤

**កថាខណ្ឌទី២ ប្រព័ន្ធទ្រព្យសម្បត្តិរួម** ........................................ ៥

១. គុណសម្បត្តិ ........................................ ៧

១.១ សិទ្ធិនិងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ........................................ ៧

១.២ សិទ្ធិនៃការចាត់ចែងលើទ្រព្យសម្បត្តិក្នុងកិច្ចសន្យាប្តីប្រពន្ធ ........................................ ៨

២. គុណវិបត្តិ ........................................ ៨

**កថាខណ្ឌទី៣ ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល** ........................................ ៨

**ផ្នែកទី២ លក្ខខណ្ឌនៃការបង្កើតទ្រព្យសម្បត្តិសហព័ទ្ធ** ........................................ ៩

**កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាសហព័ទ្ធ** ........................................ ១០

១. សមត្ថភាពភាគី (សហព័ទ្ធ) ........................................ ១២

២. ការព្រមព្រៀង ........................................ ១២

៣. កម្មវត្ថុ ........................................ ១៣

៤. អាពាហ៍ពិពាហ៍ ........................................ ១៣

**កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាសហព័ទ្ធ** ........................................ ១៤

១. នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ........................................ ១៤

១.១ ពាក្យសុំចុះបញ្ជី ........................................ ១៥

ក. កម្មវត្ថុនៃពាក្យសុំ ........................................ ១៥

ខ. ទម្រង់នៃពាក្យសុំ ........................................ ១៦

១.២ នីតិវិធីនៃការចេញលិខិតបញ្ជាក់ ........................................ ១៧

ក. របៀបដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ........................................ ១៧

ខ. ការចេញលិខិតបញ្ជាក់ ........................................ ១៨

២. លក្ខខណ្ឌតតាំង ........................................ ១៨

## ជំពូកទី២

## ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់

**ផ្នែកទី១ ចំណាត់ថ្នាក់នៃប្រព័ន្ធទ្រព្យសម្បត្តិ** ........ ២០

**កថាខណ្ឌទី១ ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ** ........ ២០

១. ទ្រព្យសម្បត្តិរបស់សហព័ទ្ធមុនអាពាហ៍ពិពាហ៍ ........ ២០

២. ទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលទទួលបានពីប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន ........ ២១

**កថាខណ្ឌទី២ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ** ........ ២១

**ផ្នែកទី២ អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ២២

**កថាខណ្ឌទី១ ចំណាត់ការលើទ្រព្យសម្បត្តិ** ........ ២២

១. ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួម ........ ២២

២. ការចាត់ចែងនូវទ្រព្យសម្បត្តិរួម ........ ២៣

៣. ការអាស្រ័យនូវទ្រព្យសម្បត្តិដោយឡែក ........ ២៤

**កថាខណ្ឌទី២ ការទទួលខុសត្រូវដោយសាមគ្គីចំពោះភាតព្វកិច្ច** ........ ២៤

១. ការទទួលខុសត្រូវក្នុងការបន្ទុកគ្រួសារ ........ ២៤

២. ការទទួលខុសត្រូវលើបំណុល ........ ២៥

២.១ ការទទួលខុសត្រូវលើបំណុលរួម ........ ២៥

២.២ ការទទួលខុសត្រូវលើបំណុលដោយឡែក ........ ២៦

## ជំពូកទី៣

## ការផ្លាស់ប្តូរ និងបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិ

**ផ្នែកទី១ ការផ្លាស់ប្តូរ និងកែតម្រូវប្រព័ន្ធទ្រព្យសម្បត្តិ** ........ ២៧

**កថាខណ្ឌទី១ ការផ្លាស់ប្តូរប្រព័ន្ធទ្រព្យសម្បត្តិ** ........ ២៨

**កថាខណ្ឌទី២ ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ២៩

**ផ្នែកទី២ ការបញ្ចប់ទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ៣១

**កថាខណ្ឌទី១ មូលហេតុនៃការបញ្ចប់** ........ ៣១

១. ការលែងលះ ........ ៣១

២. មរណភាព និងការបាត់ខ្លួន ........ ៣៣

៣. មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ ............ ៣៤

**កថាខណ្ឌទី២ ការបែងចែកទ្រព្យសម្បត្តិសហព័ទ្ធ** ............ ៣៤

១. ការបែងចែកទ្រព្យសម្បត្តិសហព័ទ្ធដោយការព្រមព្រៀង ............ ៣៤

២. ការបែងចែកទ្រព្យសម្បត្តិតាមសេចក្ដីសម្រេចរបស់តុលាការ ............ ៣៥

២.១ ការចាត់ប្រភេទទ្រព្យសម្បត្តិ ............ ៣៥

២.២ ការវាយតម្លៃទ្រព្យសម្បត្តិ ............ ៣៦

២.៣ ការប្រគល់ទ្រព្យសម្បត្តិដោយឡែក ............ ៣៦

២.៤ ការបែងចែកទ្រព្យសម្បត្តិរួម ............ ៣៦

**សេចក្ដីសន្និដ្ឋាន** ............ ៣៧

**អនុសាសន៍** ............ ៣៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

អាពាហ៍ពិពាហ៍គឺជាចំណងក្នុងការកសាងក្រុមគ្រួសារមួយរវាងបុរស និងស្ត្រីដោយមានការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត និងការបង្កើតចំណងគតិយុត្តដែលមានការទទួលស្គាល់ពីច្បាប់។ ក្រោយពីការបង្កើតចំណងអាពាហ៍ពិពាហ៍រួចហើយ ប្តីប្រពន្ធមានតួនាទីកសាងគ្រួសាររបស់ខ្លួនធ្វើយ៉ាងណាឱ្យមានសុភមង្គល និង រីកចម្រើន។ ជារឿយៗ ចំណោទតែងតែកើតមាន ថាតើក្រោយការបង្កើតចំណងអាពាហ៍ពិពាហ៍រួចទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធនិងមានការចាត់ចែងយ៉ាងដូចម្តេច?

ជាការពិតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ជាតួរអង្គសំខាន់ក្នុងរឿងអាពាហ៍ពិពាហ៍នេះដែរ ហើយដើម្បីឱ្យមានភាពសុក្រឹត្យយុត្តិធម៌ និងជួយសម្រួលកុំឱ្យមានវិវាទជម្លោះកើតឡើងកំឡុងពេលអាពាហ៍ពិពាហ៍ និងការឈានដល់ទីបញ្ចប់នៃអាពាហ៍ពិពាហ៍ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ក៏បានកំណត់អំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដោយការចែកចេញជាពីរប្រព័ន្ធគឺ **ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធកំណត់ដោយកិច្ចសន្យា** និង **ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់**។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយកិច្ចសន្យា គឺជាប្រព័ន្ធដែលកំណត់ទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងការចាត់ចែងថាទ្រព្យណាជាទ្រព្យរួម និងទ្រព្យណាជាទ្រព្យដោយឡែក ក្នុងគោលបំណងឱ្យមានភាពជាក់លាក់ច្បាស់លាស់ក្នុងការកំណត់នូវទ្រព្យសម្បត្តិទាំងនោះ ជៀសវាងនៅវិវាទផ្សេងៗដែលអាចកើតមានឡើង ហើយក្នុងការចាត់ចែងនេះត្រូវធ្វើឡើងដោយមានការព្រមព្រៀងពីប្តីប្រពន្ធទាំងសងខាង។ បន្ថែមពីនេះទៀតសោតការបង្កើតកិច្ចសន្យានេះ ក៏អាចធ្វើទៅបានមុន ឬក្រោយរៀបអាពាហ៍ពិពាហ៍ផងដែរ។[1] ប៉ុន្តែត្រូវតែបំពេញនៅលក្ខខណ្ឌមួយចំនួនដើម្បីឱ្យកិច្ចសន្យានេះមានអានុភាពនោះក្រោយបង្កើតកិច្ចសន្យាហើយ បុគ្គលដែលនិងត្រូវរៀបអាពាហ៍ពិពាហ៍ត្រូវតែទៅចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ បើពុំនោះទេ កិច្ចសន្យានោះមិនអាចយកមកតតាំងនិងតតិយជនបាននោះឡើយ។[2] ហើយក្នុងប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ ក៏ជាផ្នែកមួយជួយសម្រួល និងពន្លឿនដល់ផ្នែកតុលាការផងដែរ ដោយព្រោះតែប្រព័ន្ធនេះធ្វើការបែងចែកទ្រព្យសម្បត្តិរួចជាស្រេច ដូច្នេះក្នុងករណីដែលមានវិវាទ ឬជម្លោះដែលអាចឈានដល់ការលែងលះតុលាការនិងយកកិច្ចសន្យាទ្រព្យសម្បត្តិដែលមានការចុះបញ្ជីនោះមកធ្វើការបែងចែកតែម្តង។ ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់ គឺសំដៅទៅលើប្រព័ន្ធដែលអនុវត្តទៅតាមច្បាប់កំណត់ ដែលតម្រូវឱ្យប្តីប្រពន្ធត្រូវគោរពតាម។ ហើយក្នុងប្រព័ន្ធនេះមានការកំណត់នូវទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមផងដែរ។ ទ្រព្យដោយឡែក គឺជាទ្រព្យសម្បត្តិដែលគ្រប់គ្រងតែសហព័ទ្ធតែម្ខាង ហើយអាចចាត់ទុកជាទ្រព្យដោយឡែកបានគឺ អាចជាទ្រព្យដែលសហព័ន្ធតែម្ខាងរកមុនអាពាហ៍ពិពាហ៍ និងទ្រព្យដែលទទួលបានពីការធ្វើប្រទានកម្ម សន្តតិកម្ម អច្ច័យទាន។ ចំណែកឯទ្រព្យ

[1] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៦៩ កថាខណ្ឌ១។

[2] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧០ កថាខណ្ឌ២។

សម្បត្តិរួមភាគច្រើនគឺកើតឡើង កំឡុងពេលក្នុងចំណងអាពាហ៍ពិពាហ៍ដែលមកពីចំណូលរបស់សហព័ទ្ធទាំងសងខាង។ បន្ថែមពីនេះទៅទៀត ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ក៏បានចែងនៅការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិផងដែរ ក្នុងគោលបំណងបង្កើននៅភាពច្បាស់លាស់ ការទទួលខុសត្រូវរបស់សហព័ន្ធទាំងសងខាង។ដូច្នេះក្នុងករណីប្តីប្រពន្ធមិនមានការព្រមព្រៀងគ្នាដោយកិច្ចសន្យា នោះពេលឈានដល់ការលែងលះ តុលាការនិងធ្វើការបែងចែកទ្រព្យសម្បត្តិដោយកំណត់តាមច្បាប់ដោយស្វ័យប្រវត្តិតែម្តង។

ដោយការសម្លឹងឃើញនូវមានភាពស្មុគស្មាញ ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិរវាងប្តីប្រពន្ធបែបនេះហើយ ទើបធ្វើឱ្យយើងខ្ញុំ ជ្រើសរើសយកប្រធានបទ "ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ" នេះមកធ្វើការសិក្សាស្រាវជ្រាវដើម្បីកំណត់ និងសម្រាយឱ្យមានភាពងាយស្រួលយល់ ព្រមជាមួយភាពច្បាស់លាស់ ក្នុងការបន្សល់ទុកជាឯកសារសម្រាប់ចែករំលែកដល់មិត្តអ្នកអានដែលមានបំណងចង់សិក្សាឈ្វេងយល់បន្ថែមពាក់ព័ន្ធជាមួយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះ។

ហើយចំពោះការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរបានធ្វើការស្វែងរកឯកសារជំនួយពីប្រភពច្បាប់ដូចជា ក្រមរដ្ឋប្បវេណី២០០៧ ច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារ ប្រកាសលេខ៨១ ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី២០១១ និងកម្រងមេរៀនពីលោក លោកស្រីសាស្ត្រាចារ្យ និងឯកសារនានាផ្សេងទៀត។

បន្ទាប់ពីប្រមូលឯកសារដែលទទួលបានហើយនោះ យើងខ្ញុំទាំងពីរបានធ្វើការសិក្សាទៅលើឯកសារទាំងនោះឱ្យមានភាពលម្អិត និងច្បាស់លាស់ និងបានសម្រាយខ្លឹមសារបញ្ចូលគ្នាក្នុងការបង្កើតសារណានេះឡើង និងបានកំណត់ ចាត់ចែងចំណុចនីមួយៗឱ្យមានភាពប្រទាក់ក្រឡាគ្នា និងងាយស្រួលមើល និងអាន ដូចតទៅ៖(ជំពូកទី១) ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយកិច្ចសន្យា យើងធ្វើការបកស្រាយលម្អិតជាមួយនិងនិងទម្រង់នៃប្រព័ន្ធទ្រព្យសម្បត្តិ(ផ្នែកទី១) និងលក្ខខណ្ឌនៃការបង្កើតទ្រព្យសម្បត្តិ(ផ្នែកទី២)។ (ជំពូកទី២)ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធកំណត់ដោយច្បាប់ និងធ្វើការពិពណ៌នាអំពីចំណាត់ថ្នាក់នៃទ្រព្យសម្បត្តិ(ផ្នែកទី១) និងអានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ(ផ្នែកទី២)។ ជំពូកទី៣ ជាជំពូកចុងក្រោយ យើងនិងធ្វើការបកស្រាយពីការផ្លាស់ប្តូរ និងកែតម្រូវប្រព័ន្ធទ្រព្យសម្បត្តិ(ផ្នែកទី១) និងការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិ(ផ្នែកទី២)។

# ជំពូកទី១
# ប្រព័ន្ធទ្រព្យសម្បត្តិសហព័ទ្ធដែលកំណត់ដោយកិច្ចសន្យា

# ជំពូកទី១
# ប្រព័ន្ធទ្រព្យសម្បត្តិសហព័ទ្ធដែលកំណត់ដោយកិច្ចសន្យា

ចំណងអាពាហ៍ពិពាហ៍កើតចេញពីការព្រមព្រៀង ឬការបង្ហាញឆន្ទៈរបស់សហព័ទ្ធទាំងសងខាង។ ជាទូទៅនៅប្រទេសអឺរ៉ុបក្រោយបង្កើតចំណងអាពាហ៍ពិពាហ៍ដោយមានការចុះបញ្ជីអាពាហ៍ពិពាហ៍ រួចគឺសហព័ទ្ធមានសិទ្ធិក្នុងការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិដែលមានចែងនៅក្នុងច្បាប់របស់ប្រទេសខ្លួនដើម្បីងាយស្រួលក្នុងការបែងចែងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហព័ទ្ធនីមួយៗ។ដូចគ្នាទៅនឹងប្រទេសកម្ពុជាផងដែរ ប្រទេសកម្ពុជាក៏មានច្បាប់ក្នុងការអនុវត្តដែលស្តីអំពីប្រព័ន្ធទ្រព្យសម្បត្តិនេះដែលមានចែងនៅក្នុងច្បាប់ផងដែរ ក៏ប៉ុន្តែសហព័ទ្ធភាគីច្រើនក្រោយរៀបអាពាហ៍ពិពាហ៍ដោយមានការចុះសំបុត្រអាពាហ៍ពិពាហ៍នោះ គឺពុំមានការធ្វើចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនោះទេ ដោយគិតថាការចុះបញ្ជីទ្រព្យសម្បត្តិនេះគឺបង្កឱ្យសហព័ទ្ធម្ខាងទៀតមានការសង្ស័យ និងអន់ចិត្តដោយហេតុអ្វីបានជាមានការចុះបញ្ជីទ្រព្យសម្បត្តិទាំងដែលជាប្តីនឹងប្រពន្ធដោយរួមសុខ រួមទុក្ខជាមួយគ្នា។ ហេតុដូច្នេះ នូវពេលឈានដល់ការបញ្ចប់ជីវិតអាពាហ៍ពិពាហ៍ យើងតែងតែឃើញមានបញ្ហាទាក់ទងទៅនឹងការបែងចែកទ្រព្យសម្បត្តិដែលជាទ្រព្យសម្បត្តិផ្ទាល់ ឬទ្រព្យសម្បត្តិរួម ហើយនេះគឺជាបញ្ហាដែលកើតឡើងជារឿយៗនៅប្រទេសកម្ពុជា។

នាសម័យបច្ចុប្បន្ននេះក្តី យើងនូវតែសង្កេតឃើញប្រជាជនភាគច្រើនមិនបានចាប់អារម្មណ៍ទៅលើកិច្ចសន្យាការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិ ដោយជាគុពិតការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនេះគឺផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សហព័ទ្ធទាំងសងខាង។ដោយការធ្វើឡើងនេះបានបង្ហាញឆន្ទៈ សិទ្ធិសេរីភាព ឯករាជ្យដែលសហព័ទ្ធទទួលបាន ដោយពុំមានការបង្ខំបង្ខិតពីតតិយជន ឬភាគីណាមួយឡើយ ក៏ប៉ុន្តែប្រសិនបើភាគីម្ខាងទៀតទទួលរងការគំរាមកំហែងដោយភាគីម្ខាងទៀតនោះ ការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិពុំមានសុពលភាពឡើយ។ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការវិវត្តនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាមាន តាមដំណាក់នីមួយៗដែលមានចែងដូចជា ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៥ ក្រោយមកមានមាត្រាមួយចំនួនត្រូវបាននិរាករណ៍ដោយរាប់បញ្ចូលក្នុងក្រមរដ្ឋប្បវេណីចុះឆ្នាំ២០០៧ និងក្រោយមកទៀតមានការរាប់បញ្ចូលក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដោយក្នុងនោះមានការបែងចែកស៊ីជម្រៅបន្ថែមទាក់ទងនឹងប្រព័ន្ធទ្រព្យសម្បត្តិ និងឯកសាររបស់ក្រសួងយុត្តិធម៌ចេញស្តីអំពី ប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ដោយចង្អុលបង្ហាញអំពីនីតិវិធីនៃការបង្កើត និងចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធតាមទម្រង់បែបបទដ្ឋាននីមួយៗដែលមានចែង។

ហេតុដូច្នេះទំនាក់ទំនងប្តីប្រពន្ធគឺជាវិធានច្បាប់មួយដ៏សំខាន់ ដែលមានសិទ្ធិក្នុងការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមកិច្ចសន្យាដែលមានបញ្ញត្តិចែងនៅក្នុងក្រមរដ្ឋប្បវេណីចែងក្នុងឆ្នាំ២០០៧ដោយស្របទៅតាមវប្បធម៌ និងសង្គមរបស់ប្រទេសកម្ពុជាចំពោះបរិបទ នីតិវិធី និងទម្រង់ចុះបញ្ជីគឺត្រូវបានអនុវត្តបូករួមទាំងប្រកាសលេខ៨១ ស្តីអំពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។ ជាការពិតណាស់ ក្នុងការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធមានគោលបំណងយ៉ាងច្បាស់លាស់ដើម្បីអនុញ្ញាតឱ្យសហព័ទ្ធទាំងសងខាងយល់ដឹងយ៉ាងច្បាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិបូករួមទាំងសិទ្ធិនិងករណីយកិច្ចដែលច្បាប់អនុញ្ញាត ធ្វើយ៉ាងណាកុំឱ្យផ្ទុយទៅនឹងបញ្ញត្តិស្តីពីការទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង ។

## ផ្នែកទី១ ទម្រង់នៃប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ក្នុងកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ គឺប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់ប្រគល់សិទ្ធិនិងករណីយកិច្ចឱ្យប្តីនិងប្រពន្ធកំណត់និងធ្វើការបែងចែកទៅលើទ្រព្យសម្បត្តិដែលភាគីទាំងសងខាងទទួលបាន ដោយមានកំណត់នៅក្នុងច្បាប់ ។

នៅក្នុងការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ តែងតែមានទម្រង់ផ្សេងៗដែលត្រូវអនុវត្តតាមអាស្រ័យទៅលើសហព័ទ្ធទាំងសងខាងក្នុងការកំណត់ចង់បាន ដោយក្នុងនោះកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិសំដៅទៅលើទ្រព្យសម្បត្តិដែលមានមុនអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិអំឡុងអាពាហ៍ពិពាហ៍ ពោលគឺទ្រព្យសម្បត្តិដោយឡែក (ជាទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងសងខាងទទួលបានមុនអាពាហ៍ពិពាហ៍) និងទ្រព្យសម្បត្តិរួម។លើសពីនេះទៀតសោត ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះក៏មានចែងជាប្រព័ន្ធទ្រព្យសម្បត្តិរួមសកល រួមទាំងទម្រង់ប្រព័ន្ធផ្សេងៗដែលមានចែងនៅតាមបណ្តាប្រទេសនីមួយៗ។ ចំពោះការទាក់ទងនឹងកម្មវត្ថុ ឬទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលបានចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមានការបែងចែងយ៉ាងច្បាស់លាស់។

### កថាខណ្ឌទី១ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក

ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកគឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលបែងចែកយ៉ាងច្បាស់លាស់ មិនថាទ្រព្យសម្បត្តិនោះគឺទទួលបាន មុនឬក្រោយរៀបអាពាហ៍ពិពាហ៍ ដោយសំដៅទៅលើសហព័ទ្ធម្ខាងមានសិទ្ធិក្នុងការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិរបស់ខ្លួន ដោយផ្អែកទៅតាមហិរញ្ញវត្ថុដែលមាន ឬទទួលបានមុន ឬអំឡុង ឬក្រោយការរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលចាត់ទុកជាប្រព័ន្ធទ្រព្យសម្បត្តិដោយឡែករួមមាន៖

- ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់សហព័ន្ធម្ខាងមុនពេលរៀបអាពាហ៍ពិពាហ៍
- អំណោយឬមរតកដែលបានទទួលដោយ មុន ពេលអាពាហ៍ពិពាហ៍

- ទ្រព្យសម្បត្តិដែលទទួលបានដោយសហព័ន្ធម្ខាង ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងមិនត្រូវបានប្រើប្រាស់ដោយសហព័ន្ធផ្សេងទៀត ឬសម្រាប់ផលប្រយោជន៍នៃអាពាហ៍ពិពាហ៍
- ទ្រព្យសម្បត្តិ ឬបំណុលដែលបានកំណត់ដោយឡែកពីគ្នានៅក្នុងកិច្ចសន្យាដែលអាចអនុវត្តបានដោយស្របច្បាប់ ដូចជាកិច្ចព្រមព្រៀងមុនពេលរៀបអាពាហ៍ពិពាហ៍[3]

ជាក់ស្តែង នៅពេលសហព័ទ្ធទាំងសងខាងបានព្រមព្រៀងក្នុងការរៀបអាពាហ៍ពិពាហ៍ក្លាយជាប្តីប្រពន្ធស្របច្បាប់ដោយមានការចុះសំបុត្រអាពាហ៍ពិពាហ៍ព្រមជាមួយនិងការរួមរស់ជាមួយគ្នា ហើយជាជាក់ស្តែងក្នុងជីវិតគូរតែងតែមានការប៉ះទង្គិច និងការកកើតឡើងនូវជម្លោះនានា អាចដោយសារតែពុំមានការយោគយល់អធ្យាស្រ័យគ្នា និងអាចដោយសារបញ្ហាទាក់ទងនឹងទ្រព្យសម្បត្តិដែលភាគីទាំងសងខាងទទួលបាន ដែលនោះគឺជាទ្រព្យសម្បត្តិមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិក្រោយរៀបអាពាហ៍ពិពាហ៍។ ចំពោះបញ្ហាទ្រព្យសម្បត្តិសហព័ទ្ធទាំងសងខាងអាចនិងមានការឈ្លោះប្រកែកគ្នាទៅវិញទៅមកដោយការទាមទារនូវការបែងចែកទ្រព្យសម្បត្តិទៅតាមការចង់បានរបស់ខ្លួន ខណៈពេលដែលសហព័ទ្ធពុំទាន់យល់ច្បាស់ និងមានការភ័ន្តច្រឡំថា អ្វីទៅជាទ្រព្យសម្បត្តិដោយឡែក ហើយអ្វីទៅជាទ្រព្យសម្បត្តិរួម ដែលនេះជាគ្រឹះនៃបញ្ហាដែលបង្ក ឱ្យមានជម្លោះកើតមានឡើង។

ហេតុដូច្នេះដើម្បីបែងចែកឱ្យច្បាស់រវាងទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមនោះគឺសហព័ន្ធគួរតែធ្វើការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈ ប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។ ជាទូទៅ សម្រាប់ទ្រព្យសម្បត្តិដោយឡែកគឺមិនមានការរាប់បញ្ចូននៅពេលដែលសហព័ទ្ធធ្វើការបែងចែកទ្រព្យសម្បត្តិឡើយ ពីព្រោះទ្រព្យសម្បត្តិដោយឡែកគឺជាទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយសហព័ទ្ធតែម្ខាង ឬជាកម្មសិទ្ធិដាច់ដោយឡែក។ ក្នុងករណីមានជម្លោះកើតឡើង ដែលបង្កឱ្យមានការលុបចោលនូវអាពាហ៍ពិពាហ៍នោះ សហព័ទ្ធណាម្ខាងពុំមានសិទ្ធិទាមទារបែងចែងទ្រព្យសម្បត្តិដោយឡែកបានឡើយ។

## កថាខណ្ឌទី២ ប្រព័ន្ធទ្រព្យសម្បត្តិរួម

ប្រព័ន្ធទ្រព្យសម្បត្តិរួមជាទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន និងរកបានក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ដោយទ្រព្យសម្បត្តិរួមគឺកើតមានឡើងដោយការខិតខំប្រឹងប្រែងកម្លាំងញើសឈាមរបស់សហព័ទ្ធដែលជា ប្តីប្រពន្ធស្របច្បាប់ដោយមានការចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមច្បាប់មិនថាទ្រព្យសម្បត្តិនោះកើតចេញពីញើសឈាមរបស់សហព័ទ្ធណាម្ខាងក៏ដោយក៏នៅតែជាទ្រព្យសម្បត្តិរួមពីព្រោះភាគីទាំង

[3] យោងតាមគេហទំព័រ NOLO MH Sub I, LLC ស្តីពីប្រព័ន្ធទ្រព្យសម្បត្តិ ឆ្នាំ២០២២។

សងខាងបានសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ដោយមានការចុះសំបុត្រអាពាហ៍ត្រឹមត្រូវ។ យោងតាមស្ថានភាពបច្ចុប្បន្ននៅបរទេស ទ្រព្យសម្បត្តិសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលកម្មសិទ្ធិស្មើគ្នាចំពោះប្តីប្រពន្ធ។ ក្នុងប្រព័ន្ធទ្រព្យសម្បត្តិនេះផងដែរ សហព័ទ្ធមានសិទ្ធិក្នុងការទទួលបាន ប្រាក់ដែលរកបានដោយប្តីឬប្រពន្ធក្នុងអំឡុងពេលរៀបការ និងទ្រព្យសម្បត្តិទាំងអស់ដែលបានទិញជាមួយនឹងប្រាក់ចំណូលទាំងនោះ ជាកម្មសិទ្ធិរបស់សហព័ទ្ធទាំងសងខាង។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ទ្រព្យសម្បត្តិមួយចំនួនដែលទទួលបានក្រោយអាពាហ៍ពិពាហ៍អាចត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្បត្តិដាច់ដោយឡែក ដូចជាទ្រព្យដែលសហព័ទ្ធណាម្ខាងទទួលបានពីប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន មុនអំឡុងអាពាហ៍ពិពាហ៍។[4]

ពាក់ព័ន្ធនិងបទដ្ឋាននៅឯបរទេសវិញ ភាគីទាំងសងខាងឱ្យតែជាសហព័ទ្ធគឺគាត់មានកាតព្វកិច្ចក្នុងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដើម្បីបង្កើតឱ្យមានចំណងអាពាហ៍ពិពាហ៍កាន់តែស្និត កំណត់បង្ហាញពីភាពច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិសហព័ទ្ធ ដែលសហព័ទ្ធទាំងសងខាងទទួលបានអំឡុងអាពាហ៍ពិពាហ៍ ការបង្ហាញឆន្ទៈព្រមព្រៀងគ្នារបស់សហព័ទ្ធទាំងសងខាង ក្នុងការទទួលបានសិទ្ធិដែលសហព័ទ្ធទទួលបានក្រោយអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលអាចចាត់ទុកជាទ្រព្យសម្បត្តិរួមគឺ ប្រាក់ដែលទទួលបានជាមួយនឹងប្រាក់ចំណូល ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។នេះរួមបញ្ចូលទាំងយានជំនិះ ផ្ទះ គ្រឿងសង្ហារិម គ្រឿងប្រើប្រាស់ និងរបស់ប្រណិតៗ។[5]

ឧទាហរណ៍: លោក (ក) មានផ្ទះមួយខ្នងនៅចំណុចម៉ុផ្សារ គាត់បានជួលផ្ទះនោះក្នុងតម្លៃ១០០០ដុល្លារក្នុង១ខែ លុះដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់គាត់លោកស្រី(ខ) ដោយមានការចុះសំបុត្រអាពាហ៍ពិពាហ៍ក្លាយជា ប្តីប្រពន្ធស្របច្បាប់នោះប្រាក់ខែដែលជាថ្លៃផ្ទះជួលនោះគឺជាទ្រព្យសម្បត្តិរួមចាប់ពីថ្ងៃដែលលោក(ក)បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ(ខ) រហូតដល់ពេលរំលាយអាពាហ៍ពិពាហ៍ដោយសារតែមិនចុះសម្រុង និងមិនតាមគោលបំណងដែលភាគីទាំងសងខាងទទួលបាន។

សម្រាប់ករណីឧទាហរណ៍ខាងលើបានសបញ្ជាក់ថាលោក(ក) ថ្លៃផ្ទះជួលដែលគាត់ទទួលបានមុនអាពាហ៍ពិពាហ៍នោះគឺជាទ្រព្យសម្បត្តិដោយឡែក ដែលគាត់បានរកមកដោយខ្លួន រហូតថ្ងៃរៀបអាពាហ៍ពិពាហ៍ និងចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ (ខ) នោះថ្លៃផ្ទះជួលដែលជារបស់លោក(ក) នោះគឺជាទ្រព្យសម្បត្តិរួម រហូតមកដល់ពេលដែលត្រូវរំលាយសំបុត្រអាពាហ៍ពិពាហ៍ដោយសារតែបញ្ហាផ្ទៃក្នុងនោះ ភាគីទាំងសងខាងត្រូវមានការបែងចែកទ្រព្យរួមដែលភាគីទទួលបានក្រោយរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីភាគីណាម្ខាងមិនព្រម

[4] យោងតាមគេហទំព័រ NOLO MH Sub I, LLC ស្តីពីប្រព័ន្ធទ្រព្យសម្បត្តិ ឆ្នាំ២០២២។

[5] យោងតាមគេហទំព័រ NOLO MH Sub I, LLC ស្តីពីប្រព័ន្ធទ្រព្យសម្បត្តិ ឆ្នាំ២០២២។

ព្រៀងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ នោះសហព័ទ្ធទាំងពីរមានសិទ្ធិក្នុងការទទួលទ្រព្យសម្បត្តិរួមដោយធ្វើការបែងចែកទ្រព្យរួមនោះជាពីរ ឬក្នុងករណីពិសេស តុលាការពិចារណាទៅតាមភាពជាក់ស្តែងនៃករណីនីមួយៗ។

**១ គុណសម្បត្តិ**

ប្រព័ន្ធទ្រព្យសម្បត្តិរួម គឺជាប្រព័ន្ធដែលសមស្របមួយសម្រាប់សហព័ទ្ធក្នុងការធ្វើការបែងចែកនឹងកំណត់អំពីទ្រព្យដែលសហព័ទ្ធបានរក និងទទួលបាននៅក្នុងអំឡុងអាពាហ៍ពិពាហ៍ដើម្បីកំណត់នូវគោលបំណងនៃការបង្កើតគ្រួសារ ក៏ដូចជាពង្រឹងសាមគ្គីភាពគ្រួសាររវាងសហព័ទ្ធទាំងសងខាងឱ្យស្ថិតស្ថេរ។ លើសពីនេះ ប្រព័ន្ធទ្រព្យសម្បត្តិមានលក្ខណៈពិសេសក្នុងការការពារដល់សហព័ទ្ធដែលនៅរស់ ដោយប្រគល់ចំណែកនៃសិទ្ធិលើអចលនវត្ថុដែលជាលំនៅដ្ឋានគ្រួសារ និងបែងចែកឱ្យសហព័ទ្ធទទួលបានចំណែក ២/៣ (លើកលែងតែការប៉ះពាល់ដល់ភាគបម្រុង)។[6] បន្ថែមពីនេះទៀតប្រព័ន្ធទ្រព្យសម្បត្តិរួមបានផ្តល់នូវគុណសម្បត្តិដល់សហព័ទ្ធទាំងសងខាងក្រោយពេលចុះបញ្ជី ក៏ដូចជាការចុះធ្វើកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយរួមមាន៖

**១.១ សិទ្ធិនិងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ**

ជាទូទៅការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិដែលសហព័ទ្ធដាក់បញ្ចូល នៅក្នុងកិច្ចសន្យាដែលជាទ្រព្យសម្បត្តិប្តីប្រពន្ធទទួលបានអំឡុងអាពាហ៍ពិពាហ៍ក្រោមការបង្ហាញឆន្ទៈព្រមព្រៀងគ្នា ព្រមទាំងសិទ្ធិនិងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ។ ចំពោះសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងទ្រព្យរួមរបស់ខ្លួនក្រោយចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិរួច មានដូចជា ទំនួលខុសត្រូវរួមរបស់សហព័ទ្ធ មានន័យថាសហព័ទ្ធមានករណីយកិច្ចក្នុងការជួយសម្រួលទៅលើបញ្ហាជីវភាព រួមរបស់គ្រួសារដូចជាចំណែកសោហ៊ុយអាពាហ៍ពិពាហ៍, សំលៀកបំពាក់, ម្ហូបអាហារ, ការស្នាក់នៅដែលជាបន្ទុកទៅលើសហព័ទ្ធចំពោះការមើលថែទាំកូន។ ក្នុងករណីសហព័ទ្ធណាម្ខាងពុំគោរពទៅតាមកាតព្វកិច្ចរបស់ខ្លួន សហព័ទ្ធម្ខាងទៀតមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំទៅតុលាការឱ្យចេញនូវដីកាសម្រេចអំពីសោហ៊ុយអាពាហ៍ពិពាហ៍។[7] មួយវិញទៀតគឺការតតាំងជាមួយនឹងតតិយជន ក្នុងករណីសហព័ទ្ធណាម្ខាងបានខ្ចីម្ចាស់បំណុល (តតិយជន) ក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ ឬស្ថានភាពចាំបាច់នៅក្នុងការថែទាំគ្រួសារ នោះសហព័ទ្ធមានសិទ្ធិក្នុងការតតាំងជាមួយម្ចាស់បំណុល (តតិយជន)ដោយលើកពីបញ្ហា ចំណូលប្រចាំថ្ងៃ ដោយគាត់ជាប្រពន្ធដែលមានកាតព្វកិច្ចនៅក្នុងផ្ទះសម្រាប់ការចាយវាយ និងផ្គត់ផ្គង់បញ្ហាផ្សេងៗដែលជាបន្ទុកដូចជា ការទិញម្ហូប បង់ថ្លៃទឹកភ្លើង ថ្លៃបង់សាលារៀនកូន ដោយទាំងអស់នេះ សហព័ទ្ធម្ខាងដែលជាប្រពន្ធអាចមានសិទ្ធិលើកឡើងពីបញ្ហានេះ ពីព្រោះការងារជា

[6] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា១២៣១។

[7] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧១។

មេផ្ទះរបស់ស្ត្រីមានតម្លៃស្មើភាពជាមួយការងារខាងក្រៅផ្ទះ (ក្នុងករណីបំណុលនោះគឺខ្ចីឡើយដោយមានការព្រមព្រៀង)។ [8] ទោះបីជាសហព័ទ្ធទទួលបានផលប្រយោជន៍មែនពិតក៏ប៉ុន្តែសហព័ទ្ធទាំងសងខាងមានសិទ្ធិនឹងកាតព្វកិច្ចទាក់ទងនឹងបំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដែលកើតចេញពីការផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារ។

### ១.២ សិទ្ធិនៃការចាត់ចែងលើទ្រព្យសម្បត្តិក្នុងកិច្ចសន្យាប្តីប្រពន្ធ

ក្រោយសហព័ទ្ធទាំងសងខាងបានព្រមព្រៀងក្នុងការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធរួច សហព័ទ្ធទាំងសងខាងមានសិទ្ធិក្នុងការចាត់ចែង គ្រប់គ្រងលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកិច្ចសន្យាមានន័យថាការចាត់ចែងទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ត្រូវមានការអនុញ្ញាតយល់ព្រមពីសហព័ទ្ធម្ខាងទៀតព្រមទាំងតាមការអនុញ្ញាតពីតុលាការផងដែរ លើកលែងតែករណីចាំបាច់ទាក់ទងនឹងជីវភាពគ្រួសារ។ ជាការពិតណាស់ទោះបីសហព័ទ្ធទាំងសងខាងព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាមែនពិត ក៏ប៉ុន្តែកិច្ចសន្យានោះមានអានុភាពដោយសហព័ទ្ធម្ខាងពុំមានសិទ្ធិនៅក្នុងការរំលោភបំពានឡើយទោះបីជាខ្លួនជាប្តី ឬ ប្រពន្ធដែលជាដៃគូជីវិតឡើយ លើសពីនេះទៀតគឺមិនអាចប្រាស់ចាកពីបទបញ្ញត្តិច្បាប់ដែលបានលើកឡើងនៅក្នុងកិច្ចសន្យាឡើយ។

### ២. គុណវិបត្តិ

ក្នុងការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិ ឬការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិណាមួយតែងតែមានផលវិជ្ជមាន និងផលអវិជ្ជមាន។ ជាក់ស្តែងនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិរួមបានផ្តល់នូវផលអវិជ្ជមានដល់សហព័ទ្ធដោយសារតែមានភាពស្មុគស្មាញ ជាក់ស្តែងក្នុងប្រទេសកម្ពុជា អត្រាចំនួនតិចដែលប្តីប្រពន្ធបានធ្វើការបែងចែង ឬធ្វើការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិ មិនថាប្រព័ន្ធទ្រព្យសម្បត្តិណាមួយឡើយ មូលហេតុគឺត្រូវឆ្លងទៅតាមនីតិវិធីជាច្រើន ដែលនាំឱ្យខាតពេលវេលាចំពោះសហព័ទ្ធ។ កត្តាសំខាន់ដែលប្រជាជនខ្មែរតែងតែនិយមនិយាយគឺទំនុកចិត្ត ជាទូទៅនៅពេលដែលរៀបអាពាហ៍ពិពាហ៍ គ្រប់សហព័ទ្ធយល់ឃើញថាការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិគឺធ្វើឱ្យពួកគាត់មានការបែកបាក់នូវចំណងអាពាហ៍ពិពាហ៍ដោយហេតុថាមិនទុកចិត្តគ្នា ថែមទាំងគិតថាសហព័ទ្ធគិតតែពីទ្រព្យមិនគិតអំពីមនោសញ្ចេតនាដែលដៃគូបានផ្តល់ផ្សេងៗ។

## កថាខណ្ឌទី៣ ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល

ប្រព័ន្ធទ្រព្យសម្បត្តិសកលគឺជាទ្រព្យសម្បត្តិសហព័ទ្ធទទួលបាន ទោះបីជាក្នុងកាលៈទេសណាក៏ដោយមុនអំឡុងពេលអាពាហ៍ពិពាហ៍ ឬក្រោយពេលអាពាហ៍ពិពាហ៍មិនថាចលនវត្ថុ អចលនវត្ថុ ឬជាបំណុលផ្សេងៗដែលសហព័ទ្ធណាម្ខាងទទួលបាន។ មានន័យថាប្រព័ន្ធទ្រព្យសម្បត្តិមួយនេះគឺច្បាប់អនុញ្ញាតឱ្យភាគីប្តីឬប្រពន្ធ

[8] មាត្រា ៣៦ កថាខណ្ឌ៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ដែលមានទ្រព្យសម្បត្តិមុនអាពាហ៍ពិពាហ៍ (ទ្រព្យសម្បត្តិដោយឡែក) មិនថាជាទ្រព្យសម្បត្តិទាំងនោះគឺជាចលនវត្ថុ ឬ អចលនវត្ថុនោះ ឬបំណុលដែលភាគីណាម្ខាងទទួលបាននោះទេ គឺអាចរាប់ចូលជាទ្រព្យសម្បត្តិរួមបាន លុះត្រាតែមានការព្រមព្រៀងដោយបង្ហាញឆន្ទៈភាគីទាំងសងខាង ទើបអាចដាក់ចូលជាទ្រព្យសម្បត្តិរួមបាន។ ចំពោះការយល់ព្រមព្រៀងក្នុងការដាក់ទ្រព្យសម្បត្តិរួមនោះ គឺជាការបង្ហាញឆន្ទៈដើម្បីផលប្រយោជន៍រួម ដោយមិនមានការបង្កឡើងការបង្ខិតបង្ខំពីសហព័ទ្ធណាម្ខាងក៏ដូចជាតតិយជនណាឡើយ។

ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល និងប្រព័ន្ធទ្រព្យសម្បត្តិរួមមានលក្ខណៈស្រដៀងគ្នាដោយខុសត្រង់ថាប្រព័ន្ធទ្រព្យសម្បត្តិរួមសកលគឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងសងខាងទទួលបាន ទោះបីជានៅក្នុងរយៈពេលណាក៏ដោយ ទោះបីជាទ្រព្យមុនអាពាហ៍ពិពាហ៍ និងក្រោយអាពាហ៍ពិពាហ៍ក៏សហព័ទ្ធទាំងសងខាងទទួលបានឱ្យតែមានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត។ រីឯប្រព័ន្ធទ្រព្យសម្បត្តិរួមគឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយមានការព្រមព្រៀងដូចគ្នាក៏ប៉ុន្តែការទទួលបានទ្រព្យសម្បត្តិរួមគឺមានរយៈពេលខុសគ្នាដោយសហព័ទ្ធទាំងសងខាងទទួលបានទ្រព្យសម្បត្តិរួម ក្រោយអាពាហ៍ពិពាហ៍។

ក្រៅពីនេះយើងខ្ញុំមានការយល់ឃើញថា ប្រព័ន្ធទ្រព្យសម្បត្តិរួមសកលគឺមានអត្ថប្រយោជន៍ស្រដៀងនឹងប្រព័ន្ធទ្រព្យសម្បត្តិ២ផ្សេងទៀតដែលបានបកស្រាយខាងលើ អាស្រ័យទៅតាមប្រទេសនីមួយៗដែលបានកំណត់ ដោយការបង្កើតនោះគឺសហព័ទ្ធទទួលបាននូវការសម្រួល និងបង្កើននូវភាពជាក់លាក់រវាងសហព័ទ្ធទាំងសងខាងដូចជាចំណាត់ថ្នាក់ចែងនូវសិទ្ធិលើទ្រព្យសម្បត្តិ កាតព្វកិច្ច ក៏ដូចជាករណីយកិច្ចដែលត្រូវឱ្យសហព័ទ្ធគោរពតាមផ្សេងៗ។

## ផ្នែកទី២ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិសហព័ទ្ធ

មុនក្រមរដ្ឋប្បវេណីចូលជាធរមាននៅ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១១ និងប្រាំមួយខែក្រោយបន្ទាប់ដាក់ឱ្យអនុវត្តប្រើប្រាស់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ពាក់ព័ន្ធជាមួយនិងបញ្ហាការបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺយើងអាចយោងទៅតាមច្បាប់ អាពាហ៍ពិពាហ៍ និងគ្រួសារ។ ប៉ុន្តែមុននិងក្រមរដ្ឋប្បវេណីប្រកាសឱ្យប្រើប្រាស់គឺយើងមិនឃើញមានការប្រើប្រាស់កិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធនោះទេ តែយើងឃើញមានសញ្ញាណនៃការបែងចែកទ្រព្យសម្បត្តិរបស់សហព័ន្ធវិញ។ ជាក់ស្តែងនៅក្នុងអំឡុងនៃការលះលែងសហព័ទ្ធត្រូវបែងចែកទៅតាមការព្រមព្រៀងភាគីទាំងសងខាង នេះសបញ្ជាក់ថាទោះបីជាការបែងចែកនោះមិនកើតចេញពីការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិមែនពិតក៏ប៉ុន្តែសញ្ញាណនៃការបែងចែងទ្រព្យសម្បត្តិរវាងសហព័ទ្ធគឺប្រហាក់ប្រហែលគ្នា។

ការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធគឺបង្កើតឡើងដើម្បីទប់ស្កាត់វិវាទទំនាក់ទំនងសិទ្ធិ ករណីយកិច្ច និងជាពិសេសរឹតបន្តឹងនូវចំណងអាពាហ៍ពិពាហ៍ពាក់ព័ន្ធនិងទ្រព្យសម្បត្តិ។ ជាទូទៅបរិបទកិច្ចសន្យាប្តីប្រពន្ធគឺមានច្រើនប្រភេទទៅតាមប្រភេទទ្រព្យសម្បត្តិដែលសហព័ទ្ធចង់ដាក់ក្នុងការចុះបញ្ជីកិច្ចសន្យានោះ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាបានផ្តល់លទ្ធភាពឱ្យសហព័ទ្ធក្នុងការជ្រើសរើសនូវកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិដែលខ្លួនចង់បានជាក់លាក់។ យោងតាមលក្ខខណ្ឌចាំបាច់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីកំណត់ជាក់លាក់ទៅលើទ្រព្យសម្បត្តិមិនថាចលនវត្ថុ និង អចលនវត្ថុរបស់សហព័ទ្ធឡើង ម៉្យាងវិញទៀតគឺទំនាក់ទំនងសិទ្ធិនិងកាតព្វកិច្ចដែលសហព័ទ្ធត្រូវអនុវត្តក្រោយចុះបញ្ជីកិច្ចសន្យារួច។ ដូចដែលបានបកស្រាយខាងលើក្រោយសហព័ទ្ធបំពេញនូវការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិរួច គឺសហព័ទ្ធទទួលបានសិទ្ធិនិងករណីយកិច្ចនិងអត្ថប្រយោជន៍ផ្សេងៗក្នុងការអនុវត្តទៅតាមកិច្ចសន្យា ជាពិសេសគឺការតតាំងជាមួយតតិយជននៅក្នុងករណីមានការរំខានពីតតិយជន ឬក៏មានការរំខានពីម្ចាស់បំណុលក្នុងការទាមទារនូវសំណងមកវិញ។

ការចាប់ផ្តើមធ្វើអ្វីមួយតែងតែផ្តល់នូវចំណុចខ្វះខាតឬក៏ ខុសឆ្គងកន្លែងណាមួយ ដូចជាករណីដែលសហព័ទ្ធធ្វើការចុះបញ្ជីដោយខុសឆ្គង ដោយការភ័ន្តច្រឡំ ដែលគាត់បានដាក់ថាជាទ្រព្យសម្បត្តិដោយឡែក ឬទ្រព្យសម្បត្តិរួម ដូច្នេះសហព័ទ្ធមានសិទ្ធិក្នុងការកែប្រែថ្មីដោយផ្អែកលើការចុះបញ្ជី ក៏ ដូចជាការកែតម្រូវនូវការចុះបញ្ជីនេះ។ ក៏ប៉ុន្តែជាក់ស្តែងប្រជាពលរដ្ឋខ្មែរមួយចំនួន នៅតែពុំយល់ទៅលើអត្ថន័យនិងអត្ថប្រយោជន៍ដែលទទួលបាន ក្រោយពីការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិ។ ដោយសារតែមានការខ្វះខាតនឹងមានការយល់ច្រឡំ ហេតុនេះហើយប្រទេសកម្ពុជាបានបង្កើតប្រកាសនេះឡើងដែលស្តីអំពីប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងយុត្តិធម៌ ដែលបានចែងយ៉ាងលម្អិតក្នុងការទាក់ទងទៅនឹងការចុះបញ្ជី ក៏ដូចជាការបង្កើតកិច្ចសន្យានេះឡើង។

ដូចនេះដើម្បីឱ្យកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិ មានសុពលភាព សហព័ទ្ធនីមួយៗត្រូវតែបំពេញលក្ខខណ្ឌផ្សេងៗ ដើម្បីអាចឱ្យសហព័ទ្ធទាំងសងខាងទទួលបាននូវអត្ថប្រយោជន៍នានាតាមរយៈរបបគ្រប់គ្រងសម្បត្តិនេះ។

## កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាសហព័ទ្ធ

នៅក្នុងសង្គមខ្មែរ អាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធគឺជារឿងសំខាន់មួយនៅក្នុងជីវិតចំពោះបុគ្គល២នាក់ដោយពួកគេបានព្រមព្រៀងចាប់ដៃរួមរស់នៅជាមួយគ្នា។ ប៉ុន្តែជីវិតអាពាហ៍ពិពាហ៍គូរមួយចំនួនអាចរស់នៅមិនសមប្រកបដោយ មានការឈ្លោះប្រកែក និងរកាំរកូសក្នុងគ្រួសារ រហូតដល់មានការសម្រេចចិត្តលែងលះគ្នា។ នៅពេលដែលអាពាហ៍ពិពាហ៍ឈានដល់ការលែងលះមានចំណុចមួយចំនួន ដែលយើងមានភាពពិបាកក្នុងការ

ដោះស្រាយ នោះគឺពាក់ព័ន្ធជាមួយនិងការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដោយអាចចោទជាបញ្ហាថាតើសហព័ទ្ធនីមួយៗអាចនិងទទួលបានចំណែកទ្រព្យប៉ុន្មាន? ជាធម្មតា ប្រជាជនខ្មែរតែងតែមើលរំលងទៅលើកិច្ចសន្យាដែលធ្វើឡើងក្រោយរៀបអាពាហ៍ពិពាហ៍ដោយគាត់គិតថា ការរៀបអាពាហ៍ពិពាហ៍គឺស្ដែងឡើងពីភាពស្មោះត្រង់ក្នុងការចាប់ផ្ដើមនៃគូជីវិត ដោយការរួមរស់ជាមួយគ្នា ញ៉ាំបាយជាមួយគ្នាផ្សេងៗ ដោយមិនក្បត់គ្នាទៅវិញទៅមក។ ដោយសារតែកត្តាបែបនេះទើប គាត់មើលរំលងទៅលើកត្តាដែលអាចកើតឡើងនេះ ជាធម្មតាទេជីវិតប្ដីប្រពន្ធតែងតែកើតឡើងមាននូវការមិនចុះសម្រុងគ្នា និងកើតមានជម្លោះរហូតដល់ការជ្រើសរើសផ្លូវបំបែកដែលហៅថាការលែងលះនោះ ហេតុដូច្នេះបញ្ហាទាំងនេះគឺញ៉ាំងឱ្យមានភាពស្មុគស្មាញទៅលើការបែងចែកទ្រព្យសម្បត្តិ អាចសឹងតែជាទូទៅហើយដែលប្រទេសកម្ពុជាជួបនូវបញ្ហាប្រឈមក្នុងការដណ្ដើមយកនូវផលប្រយោជន៍រៀងៗខ្លួន ចង់ឈ្នះរៀងៗខ្លួន ដែលជាមូលហេតុដែលធ្វើឱ្យប្ដីប្រពន្ធ ឬសហព័ទ្ធដែលទើបរៀបអាពាហ៍ពិពាហ៍គួរតែជ្រើសរើសការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិនេះ ដែលជាជម្រើសងាយស្រួលក្នុងការដោះស្រាយទៅលើបញ្ហាដែលអាចកើតមានឡើងនៅក្នុងជីវិតដៃគូ។ ក្នុងករណីសហព័ទ្ធមិនបានចុះកិច្ចសន្យាទ្រព្យសម្បត្តិនោះទេ សហព័ទ្ធទាំងពីរនិងត្រូវអនុវត្ត និងបែងចែកទ្រព្យតាមប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់វិញ។

ការបង្កើតកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺធ្វើឡើងដើម្បីកំណត់យ៉ាងច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិដែលសហព័ន្ធទទួលបានមិនថាទ្រព្យសម្បត្តិនោះទទួលបានមុនអាពាហ៍ពិពាហ៍ ឬក្រោយអាពាហ៍ពិពាហ៍ក៏ដោយ និងចំណងកាតព្វកិច្ចសហព័ន្ធក្នុងតម្រូវការក្នុងគ្រួសារ ព្រមទាំងបង្ការភាពស្មុគស្មាញក្នុងការបែងចែកទ្រព្យសម្បត្តិក្នុងករណីដែលសហព័ទ្ធសម្រេចក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ហើយអាចជាកត្តាមួយក្នុងការឱ្យទំនាក់ទំនងសហព័ទ្ធមានភាពច្បាស់លាស់តម្លាភាព ក្នុងជីវិតដៃគូ។ ដើម្បីឱ្យកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិមានអានុភាព លុះត្រាតែមានការព្រមព្រៀងដោយកើតចេញពីឆន្ទៈរបស់ប្ដីប្រពន្ធ ដែលអាចសម្ដែងបានដោយគ្មានវិការៈ ព្រមជាមួយនិងការមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យាដោយមិនប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈឡើយ។ ជាពិសេសកិច្ចសន្យាដែលបង្កើតនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមិនផ្ទុយនឹងបញ្ញត្តិស្ដីពីអាហារកាតព្វកិច្ច មិនផ្ទុយនឹងបញ្ញត្តិស្ដីពីភាគបម្រុង ផ្សេងៗ។ នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិនីមួយៗត្រូវតែភ្ជាប់នូវកម្មវត្ថុដែលជា សារៈសំខាន់ថាតើ កម្មវត្ថុដែលអាចជាចលនទ្រព្យ ឬអចលនទ្រព្យនោះគឺជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធនីមួយៗ ឬគឺជាទ្រព្យសម្បត្តិរួមដែលសហព័ទ្ធទាំងសងខាងទទួលបានអំឡុងពេលអាពាហ៍ពិពាហ៍ ឬក៏ជាទ្រព្យដែលជាកម្មសិទ្ធិអវិភាគរបស់សហព័ន្ធដើម្បីកំណត់ជាកម្មវត្ថុនៅក្នុងកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិបាន លើកលែងតែសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុងតែប៉ុណ្ណោះ។ សហព័ទ្ធមានសិទ្ធិក្នុងការជ្រើសរើសនូវប្រព័ន្ធកិច្ចសន្យាណាមួយក៏បាន ដែលមានចែងនៅ

ក្នុងប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ដោយមិនស្ថិតនៅក្រោមការគំរាមកំហែងពីសំណាក់សហព័ទ្ធម្ខាងទៀត ឬតតិយជនឡើយ។

### ១. សមត្ថភាពភាគី (សហព័ទ្ធ)

ប្តីប្រពន្ធគឺជាតួអង្គសំខាន់ក្នុងការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយក្នុងការចុះកិច្ចសន្យានេះតម្រូវឱ្យសហព័ទ្ធទាំងពីរត្រូវមានសមត្ថភាពក្នុងផ្លូវច្បាប់គ្រប់គ្រាន់ពេញលេញក្នុងការចុះកិច្ចសន្យានេះ។ សមត្ថភាពតាមផ្លូវច្បាប់ជាសមត្ថភាពដែលអាចបំពេញកិច្ចការអ្វីមួយមានភាពស្របច្បាប់ត្រឹមត្រូវ រួមជាមួយគ្នានេះដែលកត្តាមានសមត្ថភាពធ្វើសកម្មភាពក៏ជាចំណុចសំខាន់ផងដែរ ដើម្បីបង្កើតឱ្យមានលទ្ធភាពធ្វើសកម្មភាព ដោយមានស្មារតីបញ្ញាគ្រប់គ្រាន់ វិនិច្ឆ័យដឹងខុសត្រូវ ដោយគ្មានការធ្វើខុស ឬផ្ទុយពីច្បាប់។ សកម្មភាពដែលអាចបញ្ជាក់ថាមានសមត្ថភាព ឬអសមត្ថភាពយើងអាចត្រួតពិនិត្យសង្កេតតាមរយៈការបង្ហាញឆន្ទៈរបស់សហព័ទ្ធ អាយុ និងស្មារតីរបស់គាត់។ ចំពោះបញ្ហាអាយុ សហព័ទ្ធទាំងពីរត្រូវមានសមត្ថភាពឆន្ទៈ (ដោយមាត្រា ១៤ នៃក្រមរដ្ឋប្បវេណី ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា សកម្មភាពដែលភាគី បានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនអាចលុបចោលបាន) បានសេចក្តីថា សហព័ទ្ធទាំងពីរត្រូវតែជាបុគ្គលដែលមានសមត្ថភាពពេញលេញមិនមែនជាអនីតិជន ឬជនដែលស្ថិតក្រោមការមើលថែរបស់អាណាព្យាបាលទូទៅ ឬក៏ស្ថិតនៅក្រោមរបបហិតូបត្ថម្ភនោះទេ។ ចំពោះបញ្ហាស្មារតី គឺចង់ផ្តោតទៅលើជនដែលមានវិល្លបស្មារតីដែលត្រូវស្ថិតក្រោមការមើលថែរបស់អាណាព្យាបាលទូទៅ ដោយមិនអាចសម្រេចលើកិច្ចការ ឬវិនិច្ឆ័យលើរឿងអ្វីមួយដោយខ្លួនឯង ដូច្នេះក្នុងករណីនេះភាគីអាចលុបចោលរាល់កិច្ចសន្យាដែលគាត់បានចុះ។[9]

### ២. ការព្រមព្រៀង

នៅក្នុងការបង្កើតកិច្ចសន្យានីមួយៗច្បាស់ណាស់ការបង្ហាញឆន្ទៈ ក្នុងការព្រមព្រៀងរវាងគូភាគីពិតជាសារៈសំខាន់។[10] ការព្រមព្រៀងគឺជាគោលការណ៍សំខាន់ក្នុងការចុះកិច្ចសន្យានានាហើយការព្រមព្រៀងនេះត្រូវបង្ហាញដោយឆន្ទៈរវាងគូភាគី ឬសហព័ទ្ធទាំងសងខាងយ៉ាងពិតប្រាកដ និងគ្មានវិការៈកើតឡើង។ ចំពោះការព្រមព្រៀងដែលតម្រូវឱ្យកើតចេញពីឆន្ទៈពិតប្រាកដ គឺមានន័យថាសហព័ទ្ធទាំងសងខាងបានយល់ដឹងពីខ្លឹមសារនៃកិច្ចសន្យានិងបានស្គាល់ពីលទ្ធផលតាមផ្លូវច្បាប់ដែលកើតចេញពីការព្រមព្រៀង។ ចំណែកឯការព្រមព្រៀងគ្មានវិការៈ គឺសំដៅទៅលើភាពគ្មានការភាន់ច្រឡំ គ្មានការឆបោក គ្មានការបង្ហាញនូវព័ត៌មានមិនពិត គ្មានការរំលោភលើស្ថានភាព និងគ្មានការគម្រាមកំហែង។

[9] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា១៤។

[10] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៣៣៧។

### ៣. កម្មវត្ថុ

ក្នុងកិច្ចសន្យាទ្រព្យសម្បត្តិ បានធ្វើការកំណត់ចំណាត់ថ្នាក់ទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរធំៗនោះគឺទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។ ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធតែម្ខាងមានសិទ្ធិក្នុងការកាន់កាប់ ហើយទ្រព្យសម្បត្តិនេះច្រើនកើតមុនអាពាហ៍ពិពាហ៍ និងការទទួលបានពីប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន។[11]ចំណែកឯទ្រព្យសម្បត្តិរួម គឺសំដៅទៅលើទ្រព្យសម្បត្តិដែលបានមកពីចំណូលរបស់ប្តីប្រពន្ធទាំងសងខាងកំឡុងពេលអាពាហ៍ពិពាហ៍។[12]

សហព័ទ្ធនិងទទួលបានសិទ្ធិ និងកាតព្វកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ មានន័យថាសហព័ទ្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម ក្នុងប្រយោជន៍រួមក្រោយចំណងអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង។[13] ហេតុដូច្នេះការចាត់ចែងទ្រព្យសម្បត្តិរួម ត្រូវតែមានការយល់ព្រមពីប្តី ឬប្រពន្ធបើពុំនោះទេ ប្តី ឬប្រពន្ធមិនអាចធ្វើការលក់ ឬ ចាត់ចែងបានឡើយ។[14] ទោះជាយ៉ាងណាមិញក្នុងការចាត់ចែង ទ្រព្យសម្បត្តិទាំងអស់គឺធ្វើយ៉ាងណាមិន ឱ្យប៉ះពាល់ដល់សិទ្ធិលើភាពបម្រុង និងអាហារកាតព្វកិច្ច ជាពិសេសត្រូវតែគោរពតាមគោលការណ៍សណ្តាប់ធ្នាប់សាធារណៈ។ ពោលគឺមិនត្រូវឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិដោយឡែកដែលទទួលបានពីប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន និងអាហារកាតព្វកិច្ចដែលភាគីសហព័ទ្ធទាំងសងខាងទទួលខុសត្រូវលើសោហ៊ុយនានា។

### ៤. អាពាហ៍ពិពាហ៍

ក្នុងការដំណើរនៃនីតិវិធីនេះឡើងមិនមែន ត្រឹមតែមានការបង្ហាញឆន្ទៈព្រមព្រៀងគ្នាពីសហព័ទ្ធនោះឡើងទេ គឺតម្រូវឱ្យមានការបញ្ជាក់បន្ថែមថាតើសហព័ទ្ធដែលមានបំណង ក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិនោះមានបានចុះបញ្ជីអាពាហ៍ពិពាហ៍ស្របតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែរឬទេ? ពីព្រោះអាពាហ៍ពិពាហ៍គឺជាកម្មវត្ថុបំណងដើម្បីឈានទៅដល់ការបង្កើតកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិនេះឡើង។ ក្នុងករណីដែលប្តីប្រពន្ធមួយគូមានបំណង ក្នុងការបង្កើតកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិនោះ ដោយពុំមានសំបុត្រអាពាហ៍ពិពាហ៍ នោះទេគាត់ពុំមានសិទ្ធិក្នុងការចុះកិច្ចសន្យាឡើយ ទោះបីជាគាត់បានរៀបអាពាហ៍ពិពាហ៍ប្រពៃណីក៏ដោយ។[15]

[11] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧២។
[12] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៣។
[13] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៦។
[14] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៦។
[15] ការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០១១ លេខ នស/រកម/០៥១១/០០៧, មាត្រា២៨។

### កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់

ជាទូទៅទម្រង់នៃកិច្ចសន្យាបែងចែកជាពីរទម្រង់ គឺកិច្ចសន្យាផ្ទាល់មាត់ និងកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាផ្ទាល់មាត់ ជាទូទៅគេប្រើចំពោះតែកិច្ចសន្យាដែលយើងប្រើប្រាស់ជាប្រចាំ ដូចជាការលក់ទិញធម្មតាតែប៉ុណ្ណោះ សម្រាប់ការធ្វើកិច្ចសន្យាធំៗដូចជាការលក់ដី ឬទិញឡានម៉ូតូ គេមិនអាចប្រើកិច្ចសន្យាផ្ទាល់មាត់បានឡើយ ដោយសារវាអាចបង្កហានិភ័យពីជនខិលខូចមួយចំនួន។ រីឯកិច្ចសន្យាជាលាយលក្ខណ៍អក្សរ គឺជាកិច្ចសន្យាដែលភាគីទាំងសងខាងធ្វើកិច្ចសន្យាដោយសរសេរជាលាយក្ខណ៍អក្សរលើក្រដាសស្នាម និងមានការបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងសងខាង។ ដូច្នេះហើយដើម្បីឱ្យមានភាពច្បាស់លាស់ និងមានអានុភាពគតិយុត្តចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរក្រោមលិខិតយថាភូត ក្នុងគោលបំណងជៀសវាងពីការកើតបញ្ហាណាមួយពិបាកក្នុងការដោះស្រាយ។ ដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធផងដែរ ដោយកិច្ចសន្យានោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្រោមទម្រង់ជាលិខិតយថាភូត ដែលមានចែងនៅក្នុងប្រកាសលេខ៨១ស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។ កិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធអាចធ្វើទៅបានលុះត្រាតែសហព័ទ្ធបានចុះសំបុត្រអាពាហ៍ពិពាហ៍ (សំបុត្រអាពាហ៍ពិពាហ៍មានសុពលភាពដោយមានការស្នើសុំចុះទៅតាមប្រកាសរបស់មន្ត្រីអត្រានុកូលដ្ឋាន) សហព័ទ្ធអាចធ្វើការស្នើសុំដាក់កម្មវត្ថុដែលទ្រព្យរបស់ខ្លួននៅក្នុងកិច្ចសន្យាតាមណាក៏បាន ហើយសហព័ទ្ធក៏មានសិទ្ធិក្នុងការស្នើសុំកែប្រែប្រសិនបើមានកន្លែងខុសឆ្គងឬក៏ចង់បន្ថែមបន្ថយទៅតាមចិត្តរបស់ខ្លួន។

#### ១. នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ

ជាទូទៅនៅក្នុងសង្គមខ្មែរ ប្ដីប្រពន្ធថ្មីថ្មោងភាគច្រើនគឺមិនចាប់អារម្មណ៍ក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធទេ ដោយគិតថាការធ្វើនូវកិច្ចសន្យានេះឡើងគឺនាំឱ្យបាត់នូវទំនុកចិត្តជាប្ដីប្រពន្ធដែលចាប់ដៃគ្នាក្នុងការបង្កើតគ្រួសារ ដោយសារតែការទុកចិត្តបែបនេះហើយទើប ក្រោយពីបញ្ចប់ចំណងអាពាហ៍ពិពាហ៍ដោយសារតែកត្តាណាមួយនៅក្នុងជីវិតប្ដីប្រពន្ធ សហព័ទ្ធទាំងសងខាងតែមានទំនាស់ក្នុងការទាមទារទ្រព្យសម្បត្តិរៀងៗខ្លួន ដោយមិនបែងចែកគ្នាឱ្យដាច់ ជាពិសេសលើបញ្ហាដីធ្លី និងផ្ទះសំបែងដែលប្រធានបទក្ដៅគគុកដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ទាំងអស់នេះហើយដែលញ៉ាំងឱ្យប្រជាពលរដ្ឋគួរតែយល់ដឹង និងចាប់អារម្មណ៍ទៅលើការចុះបញ្ជីកិច្ចសន្យាមួយនេះដើម្បីជាភាពងាយស្រួលក្នុងការទុកដាក់ ក៏ដូចជាបែងចែកក្រោយពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺក្នុងគោលបំណង អនុញ្ញាតឱ្យប្ដីប្រពន្ធ ឬបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិមុន និងក្រោយរៀបអាពាហ៍ពិពាហ៍ដើម្បីកំណត់ឱ្យច្បាស់លាស់ អំពីទំនាក់ទំនង

ទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងគោលដៅធានានូវប្រសិទ្ធិភាព និងបង្កើតអានុភាពរវាងបុគ្គលដែលត្រូវរៀបការជាមួយគ្នា ជៀសវាងនៅវិវាទដែលអាចកើតឡើងនានាក្រោយរៀបអាពាហ៍ពិពាហ៍ និងករណីលែងលះ ឬ សហព័ទ្ធទទួលមរណភាព។ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិនេះទៀតសោត បានផ្តល់នូវគុណសម្បត្តិដើម្បីតតាំងជាមួយនិងតតិយជនដែលអាចធ្វើការពារនូវការបំពានពីម្ចាស់បំណុលរបស់សហព័ទ្ធ ដូចដែលក្រមរដ្ឋប្បវេណីបានចែងនៅមាត្រា៩៧០ថា ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា។ លើសពីនេះទៀត គឺផ្តល់ភាពងាយស្រួលក្នុងការលក់ដូរ ឬ បែងចែកទ្រព្យសម្បត្តិនៅពេលដែលលះលែងកើតមានឡើង។

### ១.១ ពាក្យសុំចុះបញ្ជី

នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ គឺធ្វើឡើងជាច្រើនបែប ច្រើនយ៉ាងនិងទម្រង់នៃការចុះបញ្ជីផ្សេងៗដែលមាន កំណត់ក្នុងប្រកាសលេខ៨១ស្តីពីនីតិវិធីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅឆ្នាំ២០១៣។ គួរបញ្ជាក់ផងដែរថា ការចុះបញ្ជីកិច្ចសន្យានេះត្រូវតែធ្វើឡើងនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។ នាយកដ្ឋាន មានសិទ្ធិក្នុងការផ្លាស់ប្តូរ និងការលុបចោលនូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

#### ក. កម្មវត្ថុនៃពាក្យសុំ

អនុលោមទៅតាម សេចក្តីប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានចែងអំពីកម្មវត្ថុនៃការចុះបញ្ជីចំនួន៧ យ៉ាងដូចជា៖

- សំណើរសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំណើរសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំណើរសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាន
- សំណើរសុំចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំណើរសុំចុះបញ្ជីអំពីការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំណើរសុំចុះបញ្ជីអំពីកាលបរិច្ឆេទរៀបអាពាហ៍ពិពាហ៍
- សំណើរសុំចេញលិខិតបញ្ជាក់។

ដោយមានសំណើរខាងលើនេះ យើងអាចសរបញ្ជាក់ថាការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចធ្វើការផ្លាស់ប្តូរ កែប្រែ និងលុបចោលបាន។

រាល់ទម្រង់ឯកសារទាំងឡាយដែលត្រូវការចាំបាច់ក្នុងការចុះបញ្ជីកិច្ចសន្យា ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ សម្រាប់ឯច្បាប់ដើមត្រូវមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ចតចម្លងនៃច្បាប់ដើមនោះ។

**ខ. ទម្រង់នៃពាក្យសុំ**

ទម្រង់នៃពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិត្រូវធ្វើឡើងក្រោមទម្រង់ឬលក្ខណៈ ជាលិខិតរដ្ឋបាល តែសរសេរជាលាយលក្ខណ៍អក្សរ និង មានកម្មវត្ថុច្បាស់លាស់ ព្រមជាមួយនិងពាក្យសុំច្បាប់ដើម ដែលតម្រូវឱ្យមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃច្បាប់ដើម។

លិខិតដែលត្រូវតែមានចំណុចសំខាន់តាមលក្ខខណ្ឌដូចតទៅ៖

- បាវចនានៃព្រះរាជាណាចក្រកម្ពុជា
- ចំណងជើងនៃពាក្យសុំ
- ការគោរពកិច្ចចំពោះអ្នកទទួលលិខិត(ការគោរពជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌)
- កម្មវត្ថុ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- កាលបរិច្ឆេទធ្វើលិខិត និងហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យ។(១)ប្រការ១៦ កថាខណ្ឌទី១

ក្រៅពីចំណុចខាងលើអ្នកដាក់ពាក្យសុំក៏អាចបន្ថែមនូវចំណុចមួយចំនួនទៀតទៅតាមប្រភេទនៃពាក្យសុំផងដែរ។

សម្រាប់ឯកសារភ្ជាប់អ្នកដាក់ពាក្យត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនដល់ នាយកដ្ឋានកិច្ចការរដ្ឋប្បវេណីទៅតាមប្រភេទនៃពាក្យសុំ។ ហើយចំពោះករណីពាក្យសុំចុះបញ្ជី ដែលសាមីខ្លួនមិនបានយកមកដាក់ផ្ទាល់ ដោយឱ្យអ្នកតំណាងមកដាក់ជំនួស ត្រូវភ្ជាប់បន្ថែមជាមួយលិខិតប្រគល់សិទ្ធិតំណាង។ឯកសារទាំងអស់នោះមានដូចជា៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ក្នុងករណីដែលដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី(បញ្ជីអចលនវត្ថុ និងសៀវភៅគោលបញ្ជីដីធ្លីជាដើម។
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។
- លិខិតប្រគល់សិទ្ធិតំណាង(ប្រសិនបើមាន)[16]

ក្រោយបំពេញនូវឯកសារភ្ជាប់ផ្សេងៗរួច ត្រូវបញ្ជូនទៅមន្ត្រីចុះបញ្ជីក្នុងការទទួលពាក្យសុំចុះបញ្ជី។មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំនូវពត៌មាន[17] ដែលមានដូចជាកាលបរិច្ឆេទ និងឈ្មោះ

[16] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ៨១/ប្រក/១៣, ប្រកាស ១៩។

[17] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ៨១/ប្រក/១៣, ប្រកាស ៣៧។

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងចុះហត្ថលេខាបំពេញ និងឈ្មោះមន្ត្រីចុះបញ្ជី បន្ទាប់មកត្រូវបញ្ជូនទៅមន្ត្រីចុះបញ្ជីត្រូវសរសេរក្នុងសន្លឹកក្រដាសទទួលពាក្យសុំដែលមានដូចជា៖

- លេខរៀងទទួល
- កាលបរិច្ឆេទនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ប្រភេទនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ឈ្មោះ និងអាសយដ្ឋានអ្នកតំណាង (បើមាន)
- ផ្សេងៗ

ក្រោយមន្ត្រីចុះបញ្ជីបានពិនិត្យនឹងចុះបញ្ជី រួមទាំងឯកសារភ្ជាប់នោះមន្ត្រីចុះបញ្ជីត្រូវសរសេរក្នុងសន្លឹកចុះបញ្ជីដែលមានដូចជា៖

- ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ប្ដីប្រពន្ធ
- ខ្លឹមសារកិច្ចសន្យា
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃថ្ងៃចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទកិច្ចសន្យា[18]

## ១.២ នីតិវិធីនៃការចេញលិខិតបញ្ជាក់

### ក. របៀបដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់

របៀបនៃការដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវយកទៅដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ដោយសរសេរនៅចំណុចដូចជា៖

- គោលបំណងនៃពាក្យសុំ៖ ការសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាង នីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឱ្យចេញ លិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬស្នាមម្រាមដៃ។[19]

[18] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ លេខ៨១/ប្រក/១៣, ប្រកាស ៣៨។
[19] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ លេខ៨១/ប្រក/១៣, ប្រកាស ៤៨។

**ខ. ការចេញលិខិតបញ្ជាក់**

នៅពេលបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ទៅឱ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅឯកសារថតចម្លងថា៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ(ថ្ងៃទី.....ខែ.....ឆ្នាំ.....)
- ហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និងហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្រោយពីបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឱ្យអ្នកដាក់ពាក្យសុំនោះ យ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ថ្ងៃ។

**២. លក្ខខណ្ឌតតាំង**

ក្នុងករណីដែលប្ដីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលបានកំណត់ ដោយមិនបានចុះបញ្ជីទេ គឺមិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយតតិយជនបានឡើយ។[20] មានន័យថា ទោះបីជាប្ដីប្រពន្ធឬសហព័ទ្ធបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិដោយការព្រមព្រៀងមែនពិតក៏ប៉ុន្តែ ប្រសិនបើជាមិនបានចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិទៅតាមច្បាប់កំណត់នោះទេ នោះសហព័ទ្ធពុំមានកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិសម្រាប់ក្នុងការតតាំងជាមួយតតិយជនឡើយ ក្នុងករណីដែលតតិយជនមកតតាំងជាមួយ។ ក្នុងនោះពួកគាត់បានធ្វើនូវកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធក៏ប៉ុន្តែពួកគាត់មិនបាន ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនោះ។ ឧទាហរណ៍៖ ថ្ងៃមួយប្ដីបានខ្ចីលុយពីអ្នកស្គាល់គ្នាចំនួន១០.០០០ដុល្លារ ដើម្បីព្យាបាលជម្ងឺរបស់កូន ក៏ប៉ុន្តែខាងប្ដីមិនបានសងលុយទៅវិញ នោះម្ចាស់បំណុលបានរឹបអូសជាបណ្ដោះអាសន្ននូវដីស្រែមួយកន្លែងដែលជាទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ ដើម្បីធានាការអនុវត្តសិទ្ធិលើបំណុល។ ហេតុដូច្នេះទោះបីជាខាងប្ដីបានខ្ចីលុយដោយការព្រមព្រៀងតែម្ខាងមែនពិតក៏ប៉ុន្តែ ប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ដោយពុំមានសិទ្ធិក្នុងការតតាំងជាមួយតតិយជនដែលជាម្ចាស់បំណុល ពីព្រោះពួកគាត់ពុំបានចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិឡើយ ទោះបីទ្រព្យសម្បត្តិនោះជាទ្រព្យដោយឡែកមែនពិត ហើយមានកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមែនពិត ក៏ប៉ុន្តែមិនបានចុះបញ្ជីស្របតាមនីតិវិធីនៃការចុះបញ្ជីប្រពន្ធទ្រព្យសម្បត្តិនោះប្រពន្ធ គឺពុំមានសិទ្ធិក្នុងការតតាំងជាមួយម្ចាស់បំណុលឡើយ ។[21] កិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិមានសុពលភាពលុះត្រាតែអនុវត្តតាមប្រកាសលេខ៨១ស្ដីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ។

[20] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧០ កថាខណ្ឌទី២។

[21] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៥។

# ជំពូកទី២
# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់

# ជំពូកទី២
# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់

ជាការពិតណាស់ក្នុងបរិបទការស់នៅ និងការគ្រប់គ្រងទ្រព្យសម្បត្តិនាសម័យអតីតកាលគឺមានការប្រតិបត្តិតាមទំនៀមទំលាប់ ដោយប្រគល់ឱ្យមេគ្រួសារជាអ្នកចាត់ចែងគ្រប់គ្រងទ្រព្យទាំងអស់ ហើយមេគ្រួសារនោះគឺសំដៅទៅដល់បុរសដែលជាប្តី ក៏ព្រោះតែពួកគេជាអ្នកធ្វើការរកស៊ី ចំណែកឯនារីជាប្រពន្ធគឺមានតួនាទីជាអ្នកមើលថែផ្ទះសម្បែងតែប៉ុណ្ណោះ។ ជំនៀលក្រោយមកការផ្លាស់ប្តូរក៏កើតមានឡើងម្តងបន្តិចៗ ដោយសង្គមចាប់ផ្តើមមានច្បាប់វិន័យតឹងរឹង និងផ្តល់សិទ្ធិពេញលេញដល់ប្តីប្រពន្ធទាំងសងខាងក្នុងការជ្រើសរើសវិជ្ជាជីវៈដែលខ្លួនពេញចិត្តនិងស្រលាញ់។ ដូច្នេះប្តីប្រពន្ធអាចមានចំណូលរៀងៗខ្លួន ហើយការគ្រប់គ្រងទ្រព្យសម្បត្តិក៏មិនអាស្រ័យតាមច្បាប់ទម្លាប់ប្រពៃណីនៅសម័យមុនទៀតដែល។

សម័យកាលចេះតែដើរទៅមុខ ឯវិធានច្បាប់ក៏ចេះបង្កើតឡើងថ្មីៗក្នុងគោលបំណង ការពារសិទ្ធិ និងរៀបចំ ប្រទេសជាតិឱ្យមានសណ្តាប់ធ្នាប់ល្អ។ ហើយពាក់ព័ន្ធជាមួយច្បាប់គ្រប់គ្រងទ្រព្យសម្បត្តិក៏ត្រូវបង្កើតឡើងក្នុងគោលបំណងបញ្ចៀសនៅជម្លោះនានាដែលអាចកើតមានឡើងក្នុងកំឡុងអាពាហ៍ពិពាហ៍ ឬក្រោយលែងលះផងដែលដោយក្នុងនោះមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ជាដើមដែលបានចែងអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធពាក់ព័ន្ធជាមួយនិងសិទ្ធិ និងករណីកិច្ចផ្សេងៗរបស់ប្តីប្រពន្ធ។ គួរបញ្ជាក់ផងដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នេះគឺមានការយកគម្រូពីប្រទេសជប៉ុន ប៉ុន្តែខ្លឹមសារនានាគឺមានលក្ខណៈខុសគ្នា ដោយក្រមរដ្ឋប្បវេណីកម្ពុជាយកតាមលក្ខណៈស្របទៅតាមវប្បធម៌របស់កម្ពុជា ហើយពាក់ព័ន្ធជាមួយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធបានបញ្ញត្តិក្នុងក្រមចាប់ពី មាត្រា៩៧១ ដល់មាត្រា៩៧៧។[22]ការគ្រប់គ្រងទ្រព្យសម្បត្តិគឺអាចធ្វើទៅបានតាមកិច្ចសន្យា និងតាមច្បាប់ ប្រើសិនបើគ្មានការព្រមព្រៀងគ្នារវាងប្តីប្រពន្ធពាក់ព័ទ្ធជាមួយនិងការគ្រប់គ្រងទ្រព្យសម្បត្តិទេនោះតុលាការនិងធ្វើតាមនីតិវិធីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់ ដើម្បីឱ្យច្បាប់ជាអ្នកចាត់ចែងឱ្យ។

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់ គឺសំដៅលើការគ្រប់គ្រង ឬការបែងចែកទ្រព្យសម្បត្តិទៅតាមអ្វីដែលច្បាប់បានកំណត់ដែលតម្រូវឱ្យប្តីប្រពន្ធទាំងសងខាង គោរព និងអនុវត្តតាមគោលការណ៍នីមួយៗដែលច្បាប់បានចែង។ ហើយក្នុងនោះគោលការណ៍ជាច្រើនត្រូវបានកំណត់ឡើងសម្រាប់ប្តីប្រពន្ធក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ ព្រមជាមួយនិងការផ្តល់សិទ្ធិ និងកាតព្វកិច្ចផងដែល។ ត្រឹមមាត្រាតែ៧ ក្នុងក្រមរដ្ឋប្បវេណី គឺមិនអាចគ្រប់គ្រាន់សម្រាប់បំពេញទៅលើការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនោះទេ ដូច្នេះគោលការណ៍ច្បាប់នានាក៏ត្រូវបានបង្កើតឡើងជាបន្តបន្ទាន់ដើម្បីយិតយោងក្រមរដ្ឋប្បវេណី។ ហើយដើម្បីឱ្យមាន

[22] លោក ហ៊ីង គីមឡេង និង លោក ឆឹង ស៊ីនៀង (សិក្ខាសាលាថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ (Rule-JICA seminar 6)

ភាពងាយស្រួលក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិប្តីប្រពន្ធ ច្បាប់ក៏បានកំណត់ចំណាត់ថ្នាក់ទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរ គឺទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម ហើយនីតិវិធីនានាក្នុងការត្រូវបានចែងឡើង។ យើងនិងធ្វើការសិក្សារលម្អិតអំពីចំណាត់ថ្នាក់នៃប្រព័ន្ធទ្រព្យសម្បត្តិនីមួយៗ និងចំណុចនានា។

## ផ្នែកទី១ ចំណាត់ថ្នាក់នៃប្រព័ន្ធទ្រព្យសម្បត្តិ

ជាទូទៅប្រទេសនីមួយៗ អាចមានការចាត់ចែងចំណាត់ថ្នាក់នៃទ្រព្យសម្បត្តិរបស់សហព័ទ្ធមានភាពខុសៗគ្នារវាងប្រទេសមួយ ទៅប្រទេសមួយ។ ការកំណត់ចំណាត់ថ្នាក់ទ្រព្យសម្បត្តិនេះឡើយ ក្នុងគោលបំណងកំណត់សិទ្ធិ និង កាតព្វកិច្ចសម្រាប់ សហព័ទ្ធទាំងសងខាងក្នុងការចាត់ចែងគ្រប់គ្រងលើទ្រព្យសម្បត្តិ។ ងាយមកប្រទេសយើងវិញក៏មានការកំណត់ចំណាត់ថ្នាក់នៃប្រព័ន្ធទ្រព្យសម្បត្តិផងដែល ដែលក្នុងនោះមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដោយមានការបែងចែកជាពីរ គឺទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។ ដូច្នេះយើងនិងធ្វើការសិក្សាកាន់តែលម្អិតនៃចំណុចនីមួយៗនៃប្រភេទទ្រព្យសម្បត្តិទាំងអស់នេះ។

### កថាខណ្ឌទី១ ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ

ទ្រព្យសម្បត្តិដោយឡែក គឺសំដៅទៅលើទ្រព្យសម្បត្តិដែលស្ថិតនិងកាន់កាប់ក្រោមកម្មសិទ្ធិរបស់សហព័ទ្ធតែម្នាក់។[23] ហើយទ្រព្យសម្បត្តិដោយឡែកនេះមិនធ្វើឱ្យមានការប៉ះពាល់ដល់ទំនាក់ទំនងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធឡើយ ក៏ព្រោះតែមានតែភាគីតែម្ខាងដែលជាអ្នកគ្រប់គ្រង។បន្ថែមពីនេះទៀតសោតទ្រព្យសម្បត្តិដោយឡែកនេះកកើតឡើងមុនអាពាហ៍ពិពាហ៍ចាប់ផ្តើម ដោយភាគីសហព័ទ្ធម្ខាងនោះគាត់ខិតខំ និងធ្វើការសន្សំទុក។ លើសពីនេះទៅទៀតទ្រព្យសម្បត្តិមួយចំនួនទៀតក៏អាចចាត់ទុកជាទ្រព្យសម្បត្តិដោយឡែកផងដែល ដោយការទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន ទោះបីការទទួលបាននោះបានធ្វើឡើងក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ក្តី ក៏ការទទួលបាននៅទ្រព្យសម្បត្តិទាំងនោះ ចាត់ទុកក្នុងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកផងដែរ។ ដូច្នេះដើម្បីឱ្យកាន់តែច្បាស់ថែមទៀងយើងនិងធ្វើការសិក្សាឱ្យកាន់តែលម្អិតនៅចំណុចនីមួយៗ៖

#### ១.ទ្រព្យសម្បត្តិរបស់សហព័ទ្ធមុនអាពាហ៍ពិពាហ៍

ទ្រព្យសម្បត្តិរបស់សហព័ទ្ធមុនអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដែលភាគីសហព័ទ្ធទាំងសងខាងមានមុនអាពាហ៍ពិពាហ៍ ដោយការប្រកបរបររកស៊ី ឬធ្វើការសេន្សំប្រាក់។ ហើយទោះបីរៀបអាពាហ៍ពិពាហ៍ហើយក្តីក៏ទ្រព្យសម្បត្តិនោះនៅជាទ្រព្យដោយឡែកដដែល។ ឧទាហរណ៍ ដោយមុនចំណងអាពាហ៍ពិពាហ៍កើតឡើងប្តីបានធ្វើការរកលុយនិងសន្សំបានទិញបានផ្ទះមួយល្វែង ដូច្នេះទោះបីជារៀបអាពាហ៍ពិពាហ៍ហើយក្តីក៏ផ្ទះនោះនៅតែជាទ្រព្យដោយឡែករបស់ភាគីប្តីដដែល មិនអាចចាត់ទុកជាទ្រព្យរួមបានទេ។

[23] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧២។

### ២. ទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលទទួលបានពីប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន

ទោះបីទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលទទួលបានពីប្រទានកម្ម សន្តតិកម្ម និងបច្ច័យទាននេះមានកើតឡើងកំឡុងអាពាហ៍ពិពាហ៍ក៏ដោយ ក៏យើងអាចនៅតែចាត់ទុកវាជាទ្រព្យដោយឡែក ប្រសិនជាការផ្ទេរសិទ្ធិទាំងនោះមានតែឈ្មោះបុគ្គលតែម្នាក់។

- ប្រទានកម្ម៖ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង បង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិខ្លួន ដោយមិនគិតថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។[24] ឧទាហរណ៍៖ ក្នុងករណីនេះ ប្រសិនបើម្តាយខាងប្រពន្ធធ្វើការបង្ហាញឆន្ទៈ ប្រគល់ឡានមួយគ្រឿងឱ្យទៅកូនស្រីរបស់គាត់ដែលទើបនិងរៀបការរួច។ ដូច្នេះឡាននោះគឺត្រូវក្លាយជាទ្រព្យដោយឡែករបស់ប្រពន្ធ។
- សន្តតិកម្ម៖ គឺជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់។ ហើយសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ និងផ្អែកទៅតាមឆន្ទៈរបស់មតកជន។[25] ឧទាហរណ៍៖ ធីតា គឺជាកូនទោល របស់ ក និង ខ។ ហើយពេលនោះ (ក) ជាឪពុកបានទទួលមរណភាព ដោយបានបន្សល់នូវទ្រព្យសម្បត្តិជាទឹកប្រាក់ចំនួន៣មុឺនដុល្លា។ដោយក្នុងនោះមានបណ្តាំបានចែងថាធីតាត្រូវទទួលបាន១មុឺន។ ដូច្នេះ១មុឺនដុល្លានោះគឺជាទ្រព្យដោយឡែករបស់ធីដែលឪពុកនាងបានចែកឱ្យ។
- អច្ច័យទាន៖ គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើនអ្នកនូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។ ឧទាហរណ៍៖ តុលា(ប្តី) បានទទួលដីមួយកន្លែងពីបងប្រុសរបស់គាត់ តាមរយៈការធ្វើបណ្តាំនៅមុនគាត់បានស្លាប់។

## កថាខណ្ឌទី២ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែលប្តីប្រពន្ធទាំងសងខាង ឬម្ខាងទទួលបានក្នុងកំឡុងអាពាហ៍ពិពាហ៍។[26] កំឡុងក្នុងពេលនៃអាពាហ៍ពិពាហ៍រាល់ប្រាក់បៀវត្សចំណូលនៃសហព័ទ្ធនីមួយៗជាគោលការណ៍ត្រូវបានបញ្ចូលជាទ្រព្យសម្បត្តិរួម។ ការចូលជាទ្រព្យសម្បត្តិរួមនេះ មានគោលបំណងជួយសម្រួលដល់បន្ទុកក្នុងគ្រួសារ ព្រមជាមួយការចំណាយផ្សេងៗ និងមានផលប្រយោជន៍រួមផងដែល។ប៉ុន្តែទ្រព្យមួយចំនួនត្រូវបានលើកលែងមិនចាត់ចូលជាទ្រព្យសម្បត្តិរួមនោះគឺទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម

[24] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៥៦៨។

[25] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា១១៤៥។

[26] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៣។

អច្ច័យទាន ដោយព្រោះទ្រព្យសម្បត្តិទាំងនោះជាទ្រព្យដែលសហព័ទ្ធតែម្ខាងទទួលបានពី ឪពុក ម្តាយ ញាតិសន្តានរបស់ពួកគេ ធ្វើជាអំណោយ ឬតាមសន្តតិកម្មផ្តល់ឱ្យ។ ហើយទ្រព្យទាំងនោះត្រូវបានចាត់ជាទ្រព្យដោយឡែករបស់សហព័ទ្ធម្នាក់ៗវិញ។

## ផ្នែកទី២ អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីប្រពន្ធមានកាតព្វកិច្ច និងករណីកិច្ចក្នុងការចូលរួមចំណែកទទួលបន្ទុកលើសោហ៊ុយផ្សេងៗក្នុងជីវភាពគ្រួសារ។ ការចូលរួមទទួលបន្ទុកនេះយើងពិនិត្យទៅលើចំណូល ទ្រព្យសម្បត្តិ និងយោងទៅតាមស្ថានភាពផ្សេងៗ។ ការទទួលបន្ទុករបស់ប្តីប្រពន្ធក្នុងគ្រួសារ អាចមានដូចជា ថ្លៃម្ហូបអាហារ ថ្លៃទឹកភ្លើង ថ្លៃព្យាបាល ថ្លៃថែទាំកូនៗ និងអាចថ្លៃការអប់រំកូនជាដើម។[27] លើសពីនេះ ប្តីប្រពន្ធក៏មានការតព្វកិច្ច មើលថែគ្នា និងជួយសង្គ្រោះគ្នាទៅវិញទៅមកក្នុងការទ្រទ្រង់ជីវភាពគ្រួសារផងដែល។ ការបែងចែកទ្រព្យសម្បត្តិឱ្យមានភាពច្បាស់លាស់ជារឿងចាំបាច់ដែលគួរធ្វើ ដើម្បីជៀងវាងនៅវិវាទដែលអាចកើតឡើងនានា ការកំណត់នូវទ្រព្យសម្បត្តិមិនត្រឹមមានភាពងាយស្រួលសម្រាប់ប្តីប្រពន្ធទាំងសងនោះទេ វាក៏អាចជួលសម្រួលដល់ដំណើរការក្នុងតុលាការផងដែល។ ក្រោយពីការកំណត់ចំណាត់ថ្នាក់នៃទ្រព្យសម្បត្តិរួម យើងក៏មានចំណាត់ការក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិផងដែល ហើយនេះកាន់តែមានភាពងាយស្រួល និងមានរបៀបត្រឹមត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួម និងទ្រព្យដោយឡែកហើយ។ បន្ថែមពីនេះយើងក៏មានការបញ្ជាក់ពីការទទួលខុសត្រូវចំពោះបំណុលផងដែល ថានៅពេលដែលមានការបង្កើតបំណុល សហព័ទ្ធណាមួយជាអ្នកទទួលខុសត្រូវ និងជនណាដែលមិនតម្រូវឱ្យទទួលខុសត្រូវលើបំណុលនោះ។ តទៅនេះយើងនិងធ្វើការសិក្សាទៅលើចំណុចនីមួយៗដែលបានរៀបរាប់ខាងលើ។

### កថាខណ្ឌទី១ ចំណាត់ការលើទ្រព្យសម្បត្តិ

ចំណាត់ការលើទ្រព្យសម្បត្តិគឺសំដៅទៅលើសមត្ថភាពរបស់សហព័ទ្ធនីមួយៗក្នុងការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរួម និងបង្ហាញនៅទំហំដែនកំនត់ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងនៅទ្រព្យសម្បត្តិទាំងនោះ។ បន្ថែមពីនេះចំណាត់ការលើទ្រព្យក៏លើកឡើងក្នុងគោលបំណងបង្ហាញនូវសិទ្ធិ និងករណីកិច្ចរវាងសហព័ទ្ធទាំងសងខាងផងដែល។

#### ១. ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួម

ប្តីប្រពន្ធទាំងសងខាងមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលបានផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ន្ធនីមួយៗមានសិទ្ធិប្រើប្រាស់ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗ

[27] កម្រងមេរៀន, រៀបរៀងដោយវិភាគទានច្បាប់ ២០១៧, ទំព័រ ៤៦។

ខ្លួន។[28] ក្នុងចំណុចនេះមានន័យថាប្ដីប្រពន្ធមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរួម ក្នុងគោលបំណងផ្សេងៗ ហើយក៏ដូចជាការប្រើប្រាស់ក្នុងទំហំដែលចាំបាច់តម្រូវការសម្រាប់ជីវភាព។ យ៉ាងណាមិញការប្រើប្រាស់ទ្រព្យសម្បត្តិរួមនានាត្រូវតែមានការសហគ្នា និងការព្រមព្រៀងគ្នាពីប្ដីប្រពន្ធទាំងសងខាង។បន្ថែមពីនេះទៀតសោត សហព័ទ្ធម្ខាងអាចទាមទារទៅដល់ភាគីម្ខាងទៀតធ្វើចំណាត់ការក្នុងការគ្រប់គ្រង និងរក្សាទុកនូវទ្រព្យសម្បត្តិរួម។ ហើយបើក្នុងករណីដែលមានការពិភាក្សាអំពីការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិរួម ដែលមិនអាចសម្រេចដោយសហព័ទ្ធទាំងសងខាងបាន ភាគីសហព័ទ្ធណាម្ខាងអាចធ្វើការទាមទារទៅតុលាការ ដើម្បីឱ្យតុលាការជាអ្នកសម្រេច និងចាត់ចែងក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរួមនោះវិញ ដោយការសម្រេចនេះគឺយោងទៅតាមទិដ្ឋភាព និងការវិនិច្ឆ័យយ៉ាងល្អិតល្អន់។

**២. ការចាត់ចែងនូវទ្រព្យសម្បត្តិរួម**

ក្នុងការចាត់ចែងនូវទ្រព្យសម្បត្តិរួម ជាទូទៅត្រូវតែមានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាង បើសិនគ្មានការយល់ព្រមពីប្ដី ឬប្រពន្ធនោះទេ ទ្រព្យសម្បត្តិរួមគឺមិនអាចធ្វើការយកទៅលក់ ឬចាត់ចែងក្នុងគោលបំណងផ្សេងៗបានឡើយ។[29]ចំណុចនេះមានន័យថា ប្ដី ឬប្រពន្ធមិនអាចធ្វើការចាត់ចែងនៅទ្រព្យសម្បត្តិរួមតែម្នាក់ឯងបានទេ ដោយសារទ្រព្យសម្បត្តិនេះជាទ្រព្យរួម ដែលបានពីការខិតខំប្រឹងប្រែងធ្វើការ ឬប្រកបរបរដោយភាគីប្ដីប្រពន្ធទាំងសងខាង ដូច្នេះក្នុងការចង់លក់ ឬចាត់ចែងនានាត្រូវតែមានការពិភាក្សា សម្រេចនិងព្រមព្រៀងពីប្ដីប្រពន្ធទាំងសងខាង។ យ៉ាងណាមិញបើក្នុងស្ថានភាពដែលមិនអាចជៀងវាងបាន សម្រាប់បំពេញការថែទាំជីវភាពរស់នៅក្នុងគ្រួសារ នោះប្ដី ឬប្រពន្ធអាចធ្វើការលក់ ឬចាត់ចែងនៅទ្រព្យសម្បត្តិរួមដោយភាគីម្ខាងបានដោយទទួលបានការអនុញ្ញាតពីតុលាការ។[30] អាចមានករណីដែលចាំបាច់តម្រូវឱ្យភាគីម្ខាងជាអ្នកចាត់ចែងនៅទ្រព្យសម្បត្តិរួម ដោយតុលាការសម្លឹងឃើញថាការលក់ ឬចាត់ចែងនៅទ្រព្យរួមដោយភាគីតែម្ខាងនៃសហព័ទ្ធ គឺធ្វើឡើងក្នុងគោលបំណងផលប្រយោជន៍រួមក្នុងការថែទាំជីវភាពគ្រួសារប៉ុណ្ណោះ ដូច្នេះតុលាការអាចធ្វើការអនុញ្ញាតដល់ភាគីតែម្ខាងនៃសហព័ទ្ធក្នុងការចាត់ចែងទ្រព្យសម្បត្តិរួមនោះបាន។

ក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាង បានធ្វើការយកទ្រព្យសម្បត្តិរួមទៅលក់ ឬ ចាត់ចែងតែម្នាក់ឯង ដោយគ្មានការព្រមព្រៀង ឬយល់ព្រមពីសហព័ទ្ធម្ខាងទៀត និង គ្មានការអនុញ្ញាតពីតុលាការផងដែលនោះ សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន។ ក្នុងករណីរកឃើញថាសហព័ទ្ធរបស់ខ្លួនធ្វើការលក់ នៅទ្រព្យសម្បត្តិរួមដោយគ្មានការចចារ ឬចចារហើយតែខ្លួនមិនយល់ព្រម

---

[28] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៤។

[29] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៦, កថាខណ្ឌទី ១។

[30] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៦, កថាខណ្ឌទី ២។

ហើយភាគីសហព័ទ្ធម្ខាងទៀតនៅតែជម្នះបានធ្វើការលក់ ឬចាត់ចែងនូវទ្រព្យរួម ហើយមិនមានការអនុញ្ញាតពីតុលាការបន្ថែមទៀតនោះ ក្នុងកាលៈទេសៈបែបនេះសហព័ទ្ធដែលមិនយល់ព្រម អាចធ្វើការទាមទារទៅតុលាការឱ្យចេញសេចក្ដីសម្រេចលុបចោលការចាត់ចែងនោះបាន ដោយចំពោះអចលវត្ថុ ត្រូវប្ដឹងក្នុងកំឡុងពេល ២ឆ្នាំ គឺគិតចាប់ពីដែលបានដឹងពីការចាត់ចែងនោះ។រីឯចំពោះ ទ្រព្យសម្បត្តិផ្សេងៗ ត្រូវប្ដឹងក្នុងកំឡុងពេល ១ឆ្នាំដោយគិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះផងដែល។[31]

### ៣. ការអាស្រ័យនូវទ្រព្យដោយឡែក

ក្នុងការរួមរស់ជាប្ដីប្រពន្ធដែលលក្ខណៈគ្រួសារ ប្ដី ឬ ប្រពន្ធម្ខាងអាចធ្វើការអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀតបាន។[32] ទោះបីអចនវត្ថុនោះគឺបានកំណត់ថាជាទ្រព្យសម្បត្តិដោយឡែកក្ដី ក៏ភាគីប្ដី ឬប្រពន្ធនៅតែអាចរស់នៅទីនោះបាន ដោយសារតែប្ដីប្រពន្ធជាគោលការណ៍ត្រូវរួមរស់នៅជាមួយគ្នា បង្កើតគ្រួសារតកូនតចៅ ដូច្នេះក្នុងករណីដែលសហព័ទ្ធម្ខាងមុនរៀបអាពាហ៍ពីពាហ៍គាត់មានអចលនវត្ថុផ្ទាល់ខ្លួនរស់នៅ ហើយក្រោយពីបង្កើតចំណងអាពាហ៍ពីពាហ៍ហើយ សហព័ទ្ធទាំងពីរសម្រេចរស់នៅលើអចលនវត្ថុរបស់សហព័ទ្ធម្ខាងទៀតនោះបាន។

## កថាខណ្ឌទី២ ការទទួលខុសត្រូវដោយសាមគ្គីចំពោះកាតព្វកិច្ច

ក្រោយពីបង្កើតចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាហើយ ពិតណាស់ប្ដីប្រពន្ធត្រូវតែទទួលខុសត្រូវដោយសាមគ្គីចំពោះកាតព្វកិច្ច ដែលជាគោលការណ៍ក្នុងការបំពេញតម្រូវការក្នុងគ្រួសារ ដោយសារតែការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធតែងតែមានបន្ទុកចំណាយទៅលើជីវភាព និងការបំពេញតម្រូវការចំពោះកូនៗក៏និងមានការចំណាយផ្សេងៗផងដែល។ក្រោយពីការចំណាយទៅលើបន្ទុកគ្រួសារ សហព័ទ្ធក៏មានកាតព្វកិច្ចរួមគ្នាពាក់ព័ន្ធទៅលើការសងបំណុលរួមផងដែល ដោយការជាប់បំណុលនេះ អាចមានមូលហេតុលើការទំនុបបម្រុងជីវភាពគ្រួសារ និងមូលហេតុផ្សេងទៀតដែលយើងនិងធ្វើការបកស្រាយលម្អិតនៅខាងក្រោមនេះ៖

### ១. ការទទួលខុសត្រូវក្នុងការបន្ទុកគ្រួសារ

ការរស់នៅប្រចាំថ្ងៃរបស់គ្រួសារត្រូវមានការចំណាយទៅលើរឿងជាច្រើនដើម្បីបំពេញជីវភាព ហើយការចំណាយនេះ ក្នុងគោលការណ៍តាមច្បាប់ត្រូវតែមានការទទួលត្រូវដោយសាមគ្គីរវាងសហព័ទ្ធទាំងសងខាង ក្នុងការជួយសម្រួលបន្ទុកគ្នាទៅវិញទៅមក ហើយការចំណាយទាំងនោះអាចរួមមាន៖[33]

[31] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៦, កថាខណ្ឌទី ៣។

[32] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៧។

[33] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៥។

- សោហ៊ុយដើម្បីរក្សាជីវភាពរួមប្ដីប្រពន្ធ៖ ពោលគឺការទំនប់បម្រុងអាហារ សម្លៀកបំពាក់ សម្ភារៈ និងការធ្វើដំណើរផ្សេងៗដែលពាក់ព័ន្ធជាមួយនិងការប្រកបជីវភាពសព្វថ្ងៃ។ សហព័ទ្ធទាំងសងខាងគឺមានកាតព្វកិច្ចជួយគ្នាក្នុងការបំពេញតម្រូវការក្នុងផ្ទះទាំងអស់នេះ។
- សោហ៊ុយដើម្បីការអប់រំ ឬព្យាបាល ថែទាំកូន៖ ក្រៅពីការទទួលខុសត្រូវលើកជីវភាពប្រចាំថ្ងៃហើយសហព័ទ្ធទាំងពីរ ក៏មានកាតព្វកិច្ចក្នុងការផ្គង់ផ្គត់ដល់ការរៀនសូត្រដល់កូនៗរបស់ខ្លួនផងដែល ព្រោះក្មេងៗនៅពេលចាប់ពីអាយុ៦ឆ្នាំ ភារកិច្ចរបស់ពួកគេត្រូវចូលសាលាដើម្បីទទួលបានការអប់រំ ដូច្នេះឪពុកម្ដាយត្រូវមានកាតព្វកិច្ចបញ្ជូលកូនទៅសាលានៅពេលពួកគេគ្រប់វ័យដែកត្រូវទទួលបានការសិក្សាពេញលេញ។ បន្ថែមពីនេះទៀត សហព័ទ្ធក៏ត្រូវតែមានការមើលថៃ និងតាមដានសុខភាពកូនៗរបស់ខ្លួនឱ្យបានល្អផងដែល។ ហើយកាតព្វកិច្ចនេះ គឺឪពុកម្ដាយត្រូវតែទទួលខុសត្រូវដូចគ្នា ព្រោះជាកាតព្វកិច្ចរួម និងជាឪពុកម្ដាយត្រូវតែមានទំនួនខុសត្រូវព្រមគ្នា។

**២. ការទទួលខុសត្រូវលើបំណុល**

ការបំពេញតម្រូវការក្នុងជីវភាព គឺសហព័ទ្ធទាំងសងជាអ្នកទទួលកាតព្វកិច្ច ហើយដើម្បីបំពេញតម្រូវការនេះ ក៏អាចមានការបង្កើតបំណុលជាមួយម្ចាស់បំណុលផងដែល។គោលដៅចំពោះការបង្កើតបំណុលអាចដើម្បីប្រយោជន៍រួមក្នុងគ្រួសារ ឬដើម្បីតែប្រយោជន៍បុគ្គលតែប៉ុណ្ណោះ។ ដូច្នេះហើយការទទួលខុសត្រូវលើបំណុលក៏ត្រូវបែងចែកជាពីរដូចខាងក្រោម៖

**២.១ ការទទួលខុសត្រូវលើបំណុលរួម**

បំណុលរួម សំដៅទៅលើការបង្កើតបំណុលរវាងប្ដី ឬប្រពន្ធ ទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរជាមួយនិងម្ចាស់បំណុល ក្នុងគោលបំណងបំពេញប្រយោជន៍រួមក្នុងគ្រួសារ។ហើយការបង្កើតបំណុល ត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតជាដាច់ខាត នោះការទទួលខុសត្រូវកាតព្វកិច្ចនិងត្រូវជាការទទួលខុសត្រូវរួម។[34] ហើយការបង្កើតបំណុលនានាត្រូវតែធ្វើឡើងឱ្យមានសមល្មម សមាត្រទៅនិងជីវភាពគ្រួសារ ការដែលធ្វើវិនិយោគរបស់សហព័ទ្ធតែម្ខាង ក្នុងគោលដៅបង្កើនធនធានក្នុងគ្រួសារក៏មិនត្រូវចាត់ទុកជាបំណុលរួមឡើយ លុះត្រាការធ្វើវិនិយោគនោះ មានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត។

ដូច្នេះក្នុងករណីខាងលើចំពោះការទទួលខុសត្រូវលើបំណុលរួម ម្ចាស់បំណុលមានសិទ្ធិអាចទាមទារពីប្ដី ឬប្រពន្ធបាន ឬក៏អាចទាមទារពីសហព័ទ្ធទាំងសងខាង។

[34] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៥ កថាខណ្ឌ ខ។

### ២.២ ការទទួលខុសត្រូវលើបំណុលដោយឡែក

បំណុលដោយឡែក គឺជាបំណុលដែលមានតែភាគីសហព័ទ្ធតែម្ខាងដែលជាអ្នកទទួលបន្ទុកសងទៅម្ចាស់បំណុល។ហើយវាអាចកើតចេញពីការបង្កើតបំណុលតែជាមួយភាគីប្ដី ឬប្រពន្ធតែម្ខាង ដោយប្ដី ឬប្រពន្ធម្ខាងទៀតមិនបានយល់ព្រមព្រមព្រៀង។បន្ថែមពីនេះ បំណុលដោយឡែកក៏អាចកើតមានក្នុងគោលការណ៍ដែលការជាប់កាតព្វកិច្ចនោះមានលក្ខណៈបម្រើតែផលប្រយោជន៍ឯកជនរបស់សហព័ទ្ធតែម្ខាង នោះមានតែបុគ្គលសហព័ទ្ធនោះប៉ុណ្ណោះដែលជាអ្នកទទួលបន្ទុក។ ក្រៅពីគោលការណ៍ទាំងពីរ ប្រសិនបើសហព័ទ្ធមានជាប់បំណុល ដោយមិនមានការប្រើប្រាស់ទៅលើ ការគ្រប់គ្រង់ ជួសជុលទ្រព្យសម្បត្តិផលប្រយោជន៍ទេនោះ នោះការទទួលខុសត្រូវនោះក៏ជាការទទួលខុសលើបំណុលដោយឡែកដែល។[35]

[35] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៥។

# ជំពូកទី៣
# ការផ្លាស់ប្តូរ និងបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិ

# ជំពូកទី៣
# ការផ្លាស់ប្តូរ និងបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិ

ប្រជាជនខ្មែរភាគច្រើនធ្វើការរំលងទៅលើការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលផ្នត់គំនិតសង្គមខ្មែរគិតថា ចាប់ដៃគ្នាជាដៃគូ ប្តីប្រពន្ធរួចហើយចាំបាច់អ្វីចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ មិនទុកចិត្តគ្នា ទាំងអស់នេះដែលជាផ្នត់គំនិតប្រជាជនខ្មែរដែលបានកើតឡើងក្នុងចំណងអាពាហ៍ពិពាហ៍ដោយពួកគាត់មិនបានគិតពីគុណវិបត្តិដែលបានកើតមានឡើងនៅក្នុងចំណងអាពាហ៍ពិពាហ៍ឡើយ។ យើងមិនអាចមើលឃើញឡើយថាតើចំណងអាពាហ៍ពិពាហ៍នោះអាចដើរដល់ចំណុចណា ដូចជាក្នុងករណីដែលសហព័ទ្ធផ្តាច់នូវចំណងអាពាហ៍ពិពាហ៍របស់ខ្លួន។ ក្នុងករណីនេះសហព័ទ្ធនឹងប្រឈមនឹងការទាស់សំដីគ្នា ទាក់ទងនឹងទ្រព្យសម្បត្តិរបស់ខ្លួននីមួយៗពីព្រោះមិនដឹងថាតើប្រព័ន្ធទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិរួមដែលបានកើតឡើងនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដោយឡែកដែលសហព័ទ្ធទាំងសងខាងទទួលបានមុនអាពាហ៍ពិពាហ៍ដោយសារអច្ច័យទាន ប្រទានកម្មពីញាតិលោហិតផ្សេងៗ។ ដោយសារតែកត្តាបញ្ហានេះហើយបានជាគ្រប់សហព័ទ្ធនីមួយៗគួរតែងាកមើល និងស្វែងយល់ក្នុងការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនេះពីព្រោះការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធពិតជាផ្តល់នូវសារៈសំខាន់ចំពោះសហព័ទ្ធក៏ដូចជា ញ៉ាំងឱ្យចំណងអាពាហ៍ពិពាហ៍រឹតបន្តឹងជាមុន ជាពិសេសផ្តល់អត្ថប្រយោជន៍ដល់សហព័ទ្ធក្នុងការបែងចែកទ្រព្យសម្បត្តិណាដែលជាទ្រព្យសម្បត្តិដោយឡែកដែលសហព័ទ្ធទាំងសងខាងទទួលបាន ទ្រព្យសម្បត្តិរួមណាដែលសហព័ទ្ធខិតខំរកអំឡុងពេលអាពាហ៍ពិពាហ៍។ លើសពីនេះ ក្នុងករណីដែលតតិយជនបង្កការរំខានដល់សហព័ទ្ធ នោះសហព័ទ្ធមានសិទ្ធិក្នុងការតតាំងដោយលើកបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនោះជាភស្តុតាង។ ក្នុងការចុះបញ្ជីទ្រព្យសម្បត្តិនេះផងដែរសហព័ទ្ធមានសិទ្ធិក្នុងការជ្រើសរើសការប្រព័ន្ធទ្រព្យសម្បត្តិណាដែលខ្លួនពេញចិត្ត ដូចដែលមានចែងនៅក្នុងប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ហើយសហព័ទ្ធមានសិទ្ធិក្នុងការដាក់កម្មវត្ថុអ្វីដែលសហព័ទ្ធចង់បាន ក៏ដូចជាការកែតម្រូវ និងការផ្លាស់ប្តូរផ្សេងៗប្រសិនបើខុសឆ្គងកន្លែងណាមួយ។

## ផ្នែកទី១ ការផ្លាស់ប្តូរ និងកែតម្រូវប្រព័ន្ធទ្រព្យសម្បត្តិ

សហព័ទ្ធមានសិទ្ធិក្នុងការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិ ក្នុងប្រភេទណាមួយក៏បានដែរ ដោយមានសិទ្ធិក្នុងការកំណត់នូវកម្មវត្ថុ ក៏ដូចជាកំណត់តើប្រព័ន្ធនោះជាប្រព័ន្ធដោយឡែក ឬ ប្រព័ន្ធទ្រព្យសម្បត្តិរួម ដោយការកំណត់នោះច្បាស់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈរបស់សហព័ទ្ធទាំងសងខាង។ ក្នុងករណីដែលការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិធ្វើឡើងដោយការបង្ខិតបង្ខំ ក៏ដូចជាធ្វើឡើងដោយមិនមានជូនដំណឹងទៅសហព័ទ្ធម្ខាងទៀត

នោះ ការអនុវត្ត ពុំមានប្រសិទ្ធភាពឡើយ។ ក្នុងការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនោះ ប្រសិនបើសហព័ទ្ធមានបំណងក្នុងការកែប្រែ ដោយពិនិត្យមើលទៅខុសអក្ខរាវិរុទ្ធ ក៏ដូចជាខុសផ្នែកណាមួយនៃប្រព័ន្ធទ្រព្យសម្បត្តិដែលបានចុះបញ្ជីនោះ សហព័ទ្ធមានសិទ្ធិក្នុងការកែប្រែដោយយោងទៅតាមប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។ មួយវិញទៀតប្រសិនបើសហព័ទ្ធមានឆន្ទៈក្នុងការផ្លាស់ប្តូរបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិដោយខ្លួនបានធ្វើ នោះសហព័ទ្ធក៏ត្រូវតែគោរពតាមបញ្ញត្តិដែលមានចែងនៅក្នុងប្រកាសលេខ៨១ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ផងដែរ ទើបសហព័ទ្ធអាចទទួលបានសិទ្ធិក្នុងការផ្លាស់ប្តូរបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិរបស់ខ្លួនបាន។

### កថាខណ្ឌទី១ ការផ្លាស់ប្តូរប្រព័ន្ធទ្រព្យសម្បត្តិ

នៅពេលដែលប្តីប្រពន្ធបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចរាល់ហើយ នោះមានន័យថាសហព័ទ្ធទាំងសងខាងបានព្រមព្រៀងគ្នាទទួលយកនិង យល់ស្របអនុវត្តនៅបញ្ញត្តិច្បាប់ដែលបានចែងអំពីកាតព្វកិច្ច និងសិទ្ធិរបស់សហព័ទ្ធម្នាក់ៗ។ ប៉ុន្តែក្រោយពីបានអនុវត្តនៅបញ្ញត្តិទាំងអស់នោះហើយ ប្រសិនបើសហព័ទ្ធទាំងសងខាងមានបំណងចង់ធ្វើការផ្លាស់ប្តូរ ឬកែតម្រូវនៅចំណុចណាមួយសហព័ទ្ធទាំងពីរគឺអាចធ្វើទៅបាន តែត្រូវមានការព្រមព្រៀងពីសហព័ទ្ធទាំងសងខាង និងមានការធ្វើលិខិតស្នើសុំផ្លាស់ប្តូរ ឬកែតម្រូវជាលាយលក្ខណ៍អក្សរទៅស្ថាប័នដែលពាក់ព័ន្ធដើម្បីធ្វើការចុះបញ្ជីជាថ្មី នោះទើបការផ្លាស់ប្តូរ ឬ កែតម្រូវនៃចំណុចនានាមានអានុភាព បើពុំមានការចុះបញ្ជីជាថ្មីនោះទេ គឺមិនអាចយកចំណុចទាំងនោះទៅតតាំងជាមួយតតិយជនបាននោះទេ។

ចំពោះការធ្វើការផ្លាស់ប្តូរនេះទៀតសោត ត្រូវតែមានការធ្វើឡើងជាបើកចំហ និងផ្តល់សិទ្ធិទៅដល់សហព័ទ្ធទាំងសងខាង ហើយត្រូវតែមានការយល់ព្រមពីសហព័ទ្ធទាំងពីរជាដាច់ខាត និងពុំមានការផ្ទុយទៅនិងច្បាប់។ ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ភាគច្រើនគឺផ្លាស់ប្តូរទៅលើចំណុចនៃប្រភេទនៃទ្រព្យសម្បត្តិ ការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ដូចជាការផ្លាស់ប្តូរនូវប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធទៅជាប្រភេទថ្មីមួយទៀត។

ឧទាហរណ៍៖ ប្តីប្រពន្ធពូសម និងមីងចាន់ក្រោយពីបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងបានអនុវត្តហើយផងដែរនោះ ពួកគាត់មានបំណងចង់ផ្លាស់ប្តូរនៅចំណុចមួយនៃប្រភេទនៃទ្រព្យសម្បត្តិពីទ្រព្យសម្បត្តិដោយឡែក ទៅជាទ្រព្យរួមដោយពួកគាត់យល់ឃើញថាការផ្លាស់ប្តូរនៅចំណុចមួយនេះ អាចជួយសម្រួលបន្ទុកក្នុងគ្រួសារ។

ក្រោយពីមានការព្រមព្រៀងគ្នារួចរាល់ហើយ ការផ្លាស់ប្តូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវតែដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ ព្រមភ្ជាប់ជាមួយនិងមូលហេតុច្បាស់នៃការផ្លាស់ប្តូរផងដែរ។

បន្ថែមពីនេះទម្រង់នៃពាក្យសុំចុះបញ្ជីត្រូវសរសេរបន្ថែមនៅចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្តូរ)

ឃ. ចំណុចដែលត្រូវផ្លាស់ប្តូរ

ង. ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី

ច. ឈ្មោះ ឬ អាសយដ្ឋានថ្មី។

ក្រោយពីនោះក៏ត្រូវភ្ជាប់ជាមួយឯកសារផងដែរមានដូចជា៖

ក. កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ខ.សាលក្រម ឬដីកាសម្រេចផ្លាស់ប្តូរ

គ.លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន

ឃ. វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ។

ង. លិខិតប្រគល់សិទ្ធិតំណាង(ប្រសិនបើមាន)

ច. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។[36]

## កថាខណ្ឌទី២ ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺសំដៅទៅលើកិច្ចសន្យាដែលបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬខកខានមិនបានចុះបញ្ជី ប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។[37]

ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមានកំហុស ចំណុចនេះមានន័យថាបើប្តីប្រពន្ធបានធ្វើការចុះបញ្ជីរួចរាល់ហើយ ប៉ុន្តែពិនិត្យឃើញមានកំហុសណាមួយនៅលើកិច្ចសន្យាចុះបញ្ជីនោះ ប្តីប្រពន្ធមានសិទ្ធិដាក់ពាក្យស្នើរសុំដើម្បីកែតម្រូវកិច្ចសន្យានោះ។

ឧទាហរណ៍៖ ពូចន និងមីងពីនបានទៅធ្វើការចុះបញ្ជីនៅកិច្ចសន្យាទ្រព្យសម្បត្តិរបស់គាត់ហើយក្រោយពីចុះបញ្ជីរួចរាល់ហើយពូចនបានពិនិត្យការចុះបញ្ជីនោះ មានកំហុសដោយការសរសេរឈ្មោះរបស់គាត់ខុស។ ដូច្នេះពូចនមានសិទ្ធិក្នុងការដាក់ពាក្យសុំកែតម្រូវឡើងវិញ។

[36] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ២០។

[37] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ២១។

ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិដោយមានការខកខានមិនបានចុះបញ្ជីគឺសំដៅទៅលើការកែតម្រូវបន្ថែមនៅទ្រព្យសម្បត្តិណាមួយដែលបានខកខានមិនបានចុះបញ្ជី។

ឧទាហរណ៍៖ ប្តីប្រពន្ធពូសមមីងពីនបានទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរបស់គាត់ ហើយក្រោយពីបានចុះបញ្ជីរួចរាល់ហើយ ពូសមបាននឹកឃើញថាមិនទាន់បានចុះបញ្ជីនៅទ្រព្យសម្បត្តិរបស់គាត់មួយកន្លែង។ ក្នុងករណីនេះពូសម និងមីងពីនអាចដាក់ពាក្យស្នើសុំចុះបញ្ជីក្នុងការបំពេញបន្ថែមនៅចំណុចដែលខកខានទាំងនោះ។

ក្រោយពីបានឃើញថាមានកំហុស និងខកខាននៅក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិនោះហើយសហព័ទ្ធ ឬអនាគតប្តីប្រពន្ធ ត្រូវរៀបចំដាក់ពាក្យសុំធ្វើការកែតម្រូវនៅការចុះបញ្ជីនៃកិច្ចសន្យាទ្រព្យសម្បត្តិនោះដោយទម្រង់នៃពាក្យសុំចុះបញ្ជីត្រូវសរសេរបន្ថែមនៅចំណុចមួយចំនួនដូចជា៖

ក. គោលបំណង

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

ឃ. ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន
- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ក្រៅពីនោះក៏ត្រូវភ្ជាប់ជាមួយឯកសារ៖

ក. កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ខ. សំបុត្រអាពាហ៍ពិពាហ៍

គ. វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការកែតម្រូវ។

ឃ. លិខិតបញ្ជាក់អាសយដ្ឋាន

ង. លិខិតប្រគល់សិទ្ធិតំណាង(ប្រសិនបើមាន)

ច. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។[38]

[38] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ២១។

## ផ្នែកទី២ ការបញ្ចប់ទ្រព្យសម្បត្តិប្ដីប្រពន្ធ

ដំណើរនៃជីវិតគូរគឺយើងពុំអាចស្មានដឹងថានិងអាចដើរដល់ទីបញ្ចប់ជាមួយគ្នា ឬក៏ដើរបានត្រឹមពាក់កណ្តាលផ្លូវ ព្រោះក្នុងដំណើរនេះអាចមានភាពរកាំរកូស និងបញ្ហាកើតមានឡើង។ គូរខ្លះក៏សម្រេចចិត្តបញ្ចប់ចំណងអាពាហ៍ពិពាហ៍នោះ ហើយបើប្តីប្រពន្ធសម្រេចចិត្តក្នុងការរំលាយអាពាហ៍ពិពាហ៍ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានសម្រេចរំលាយកំជាប់ពាក្យ ប្តីប្រពន្ធ ឬបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។[39] ព្រោះកាលណាអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យត្រូវបានរំលាយ ការសើរើបែងចែកទ្រព្យសម្បត្តិក៏ត្រូវកើតមានឡើង និងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏ត្រូវបានលុបចោលផងដែរ។ ហើយការស្នើសុំដាក់ពាក្យលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏តម្រូវឱ្យ ធ្វើឡើងជាការលាយលក្ខណ៍អក្សរជាអក្សរទៅកាន់ស្ថាប័នដែលពាក់ព័ន្ធ។

នៅពេលចំណងអាពាហ៍ពិពាហ៍អាចនិងមិនសមប្រកបចំពោះគូរប្តីប្រពន្ធមួយចំនួន ដោយគូរខ្លះដើរជាមួយគ្នាត្រឹមពាក់កណ្តាលផ្លូវក៏ត្រូវផ្តាច់ចំណងអាពាហ៍ពិពាហ៍ទៅហើយ ទ្រព្យសម្បត្តិក៏ត្រូវលើមកជាប្រធានបទយកមកនិយាយផងដែរ។ ដូច្នេះតើការបញ្ចប់ចំណងអាពាហ៍ពិពាហ៍មានការជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះទៅលើប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធ?

### កថាខណ្ឌទី១ មូលហេតុនៃការបញ្ចប់

ការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយសារតែចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធអាចកើតមានឡើង ក៏ព្រោះតែមានចំណងអាពាហ៍ពិពាហ៍រវាងបុគ្គលពីរូបផ្សារភ្ជាប់ទំនាក់ទំនងគ្នាដែលឈានដល់ការរៀបអាពាហ៍ពិពាហ៍នោះដែរ។ បន្ថែមពីនេះទៀតសោត កំឡុងមានចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងសងខាងមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិទាំងអស់នោះ។ ដូច្នេះនៅពេលបញ្ចប់ចំណងអាពាហ៍ពិពាហ៍ វាក៏តម្រូវឱ្យទាញយកនៅការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិផងដែរ ហើយខាងក្រោមនេះគឺមូលហេតុនៃការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ។

#### ១. ការលែងលះ

ការលែងលះ គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបការការពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់។[40] ការរស់នៅជាជីវិតប្តីប្រពន្ធអាចមានការមិនសមប្រកប ដោយមានការកើតឡើងនៅវិវាទបញ្ហា ដែលធ្វើឱ្យភាគីសហព័ទ្ធណាមួយមិនអាចរួមរស់បន្តទៅមុនជាមួយសហព័ទ្ធម្ខាងទៀតបាន ដែលហេតុនាំ

[39] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ២២។

[40] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា៣៨។

ឱ្យឈានដល់ការលែងលះ។

ដើម្បីឱ្យមានភាពយុត្តិធម៌ និងជាអំណះអំណាងក្នុងគោលបំណងចង់លែងលះ ជៀសវាងនៅបញ្ហាដែលអាចកើតមានឡើង និងការតវ៉ាប្រឆាំងមិនយល់ព្រមពីសហព័ទ្ធម្ខាងទៀត ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជានៅមាត្រា៩៧៨ និង ៩៧៩ បានចែងអំពីការអនុវត្តទៅបានអំពីការលែងលះតាមពីរបែបគឺ ការលែងលះដោយដាក់ពាក្យសុំលែងលះ និងការលែងលះដោយមានការព្រមព្រៀងពីសហព័ទ្ធទាំងសងខាង។ ការលែងលះដោយដាក់ពាក្យបណ្ដឹងទៅបានភាគីសហព័ទ្ធត្រូវភ្ជាប់នៅមូលហេតុដូចករណីខាងក្រោម៖

- អំពើផិតក្បត់៖ នៅពេលដែលសហព័ទ្ធណាម្ខាងប្រព្រឹត្តអំពើផិតក្បត់ ដោយលួចទៅមានជនទី៣ ក្នុងករណីនេះសហព័ទ្ធម្ខាងទៀតមានសិទ្ធិ ក្នុងការដាក់ពាក្យបណ្ដឹងសុំលែងលះទៅតុលាការបាន។ ឧទាហរណ៍៖ ប្រពន្ធបានចាប់បានប្ដីរបស់ខ្លួនកំពុងរួមភេទជាមួយនារីផ្សេង ដោយរឿងនេះធ្វើឱ្យគាត់ខូចចិត្ត និងពុំអាចទទួលស្វាមីរបស់គាត់បានទៀត ដូច្នេះស្ត្រីជាភរិយាមានសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងលែងលះបុរសជាស្វាមីរបស់គាត់ ដើម្បីបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់គាត់ទាំងពីរ។
- ការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុ៖ ក្នុងករណីដែលសហព័ទ្ធម្ខាងធ្វើការបោះបង់ ឬចាកចេញសហព័ទ្ធម្ខាងទៀតដោយគ្មានមូលហេតុ អស់រយៈពេលយូរ ភាគីនៃសហព័ទ្ធម្ខាងទៀតមានសិទ្ធិដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីធ្វើការលែងលះ។ ឧទាហរណ៍៖ សហព័ទ្ធដែលជាប្រពន្ធបានធ្វើការចុះចោលប្ដីរបស់ខ្លួន ដោយមិនប្រាប់ពីមូលហេតុនៃការចុះចេញនោះ ហើយបានទុកប្ដី និងកូនចោល។ ដូច្នេះបុរសជាប្ដីមានសិទ្ធិដាក់ពាក្យបណ្ដឹងសុំលែងលះបាន។
- ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់៖ គឺការមិនទទួលបានពត៌មាន ឬដំណឹងអ្វីពីសហព័ទ្ធរបស់ខ្លួន ដែលមិនថាទៅណា ស្លាប់ ឬក៏រស់អស់រយៈពេលជាង១ឆ្នាំ។ ការបាត់ដំណឹងនេះសហព័ទ្ធម្ខាងទៀតមានសិទ្ធិក្នុងដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការ។ ឧទាហរណ៍៖ ពូសុខជាប្ដីរបស់មីងសាន្តបានធ្វើដំណើរទៅរកស៊ីនៅឯស្រុកឆ្ងាយ ហើយអស់រយៈពេលជាង១ឆ្នាំ មីងសាន្តបានបាត់ដំណឹងប្ដីរបស់គាត់ គ្មានទំនាក់ទំនង និងដំណឹងអ្វីពីប្ដីរបស់គាត់សោះ។ ក្នុងករណីនេះ មីងសាន្តអាចជូនដំណឹង និងដាក់ពាក្យបណ្ដឹងទៅតុលាការបាន។
- ការរស់នៅបែកពីគ្នា ៖ ក្នុងករណីនេះគឺសហព័ទ្ធទាំងពីរបានរស់បែកពីគ្នា ដោយមិនមានការរួមរស់ជាមួយគ្នាអស់រយៈពេលជាង១ឆ្នាំ ដែលនេះមានភាពផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ដែលជាធម្មតាប្ដីប្រពន្ធត្រូវតែមានការរួមរស់ជាមួយគ្នាក្នុងផ្ទះតែមួយ។ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។

ឧទាហរណ៍៖ ការរស់នៅជីវិតជាប្ដីប្រពន្ធរវាងសំ និងណាងតែងតែមានភាពរង្គោះរង្គើដោយតែងតែមានជម្លោះកើតឡើង រហូតដល់ថ្ងៃមួយណាងបានរត់ទៅរស់នៅផ្ទះឪពុកម្ដាយគាត់វិញ ដោយគ្មានការសម្របសម្រួលពីពីរភាគីទាំងសងខាង ពួកគេបានរស់នៅបែកពីគ្នារហូតអស់រយៈពេលជាង១ឆ្នាំ។ ដូច្នេះក្នុងករណីនេះភាគីណាមួយអាចដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីសុំឱ្យតុលាការចេញសាលក្រមលែងលះដល់ពួកគាត់ទាំងពីរ។

- ករណីផ្សេងៗដែលធ្វើឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់៖ ក្នុងចំណុចនេះ គឺសំដៅទៅលើករណីដែលមានសភាពលំបាក និងគ្មានសង្ឃឹមថានិងអាចមានភាពត្រូវរ៉ូវ ឬផ្សះផ្សារគ្នាវិញបាន ដោយបញ្ហាដែលកើតឡើងអាចធ្វើភាគីនៃសហព័ទ្ធពិបាកនិងទទួលយក។ ដោយហេតុដូចនេះសហព័ទ្ធម្ខាងមានសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងសុំលែងលះបាន។ឧទាហរណ៍៖ បុរសជាប្ដីតែងតែប្រើអំពើហិង្សាទៅលើប្រពន្ធរបស់គាត់ ដោយមានការរងទុក្ខពីអំពើហិង្សារពីប្ដីរបស់ខ្លួនជារឿយៗ នារីជាប្រពន្ធបានសម្រេចថាមិនអាចទ្រាំទ្រ និងរស់នៅជាមួយប្ដីរបស់គាត់បានទៀតទេ។ ដោយមូលហេតុនេះគាត់អាចធ្វើការដាក់ពាក្យបណ្ដឹងសុំលែងលះបាន។
- ការលែងលះដោយមានការព្រមព្រៀងពីសហព័ទ្ធ គឺសំដៅទៅលើភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។ [41] នេះគឺការបញ្ចប់អាពាហ៍ពិពាហ៍ ដែលមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង ដោយមូលហេតុ ផ្សេងៗដែលធ្វើឱ្យពួកគាត់យល់ឃើញថាពួកគាត់មិនអាចបន្ត ឬរួមរស់ជាមួយគ្នាទៀតបានទេ ដូច្នេះសហព័ទ្ធទាំងពីរអាចធ្វើការដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីធ្វើការលែងលះ។ ឧទាហរណ៍៖ កញ្ញា និងបេន បានព្រមព្រៀងគ្នាធ្វើការលែងលះបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេ ដោយពួកគេយល់ឃើញថាពួកគេមិនអាចរួមរស់ជាមួយគ្នាបាន។

### ២. មរណភាព និងការបាត់ខ្លួន

នៅពេលដែលភាគីនៃសហព័ទ្ធណាមួយទទួលមរណភាព នោះក្នុងចំណងអាពាហ៍ពិពាហ៍ពួកគេក៏ត្រូវបានបញ្ចប់ ដោយហៅថាចំណងអាពាហ៍ពិពាហ៍គឺយើងសំដៅទៅលើមនុស្សពីរនាក់ ហេតុដូច្នេះនៅពេលដែលភាគីម្ខាងបានទទួលមរណភាព នោះនិងគ្មានចំណងអាពាហ៍ពិពាហ៍កើតឡើងនោះទេ។ ចំពោះការបាត់ខ្លួន គឺជាការពុំបានទទួលដំណឹងពីសហព័ទ្ធរបស់ខ្លួន និងមិនដឹងច្បាស់លាស់អំពីការអវត្តមានរស់ ឬស្លាប់របស់សហព័ទ្ធរបស់គាត់ក្នុងកំឡុងពេល៥ឆ្នាំ ។ហើយក្នុងកំឡុងពេល៥ ឆ្នាំនោះតុលាការអាចធ្វើការប្រកាសអំពីការបាត់ខ្លួន

[41] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧ មាត្រា៩៧៥។

របស់បុគ្គលនោះបាន។ ហើយក្នុងចំណុចខាងលើក៏អាចធ្វើការយកមកប្រើប្រាស់ក្នុងករណីដែលបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានកិច ឬបុគ្គលដែលបានជួបប្រទះ និងគ្រោះថ្នាក់ផ្សេងៗទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ១ឆ្នាំ។[42] តាមករណីខាងលើ មរណភាពឬបាត់ខ្លួននេះដែលជាមូលហេតុបណ្តាលឱ្យមាន ការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ និងជាហេតុដែលឈានដល់ការបែងចែកទ្រព្យសម្បត្តិ។ ហើយការបែងចែកនេះគឺសំដៅទៅលើការបែងចែកទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។ ទ្រព្យសម្បត្តិដោយឡែក គឺតម្រូវឱ្យមានការបែកចែកជូនរៀងៗខ្លួនទោះបីគ្មានវត្តមានរបស់សហព័ទ្ធម្ខាងដែលបានទទួលមរណភាព ឬបាត់ខ្លួនក៏ដោយ។ ចំណែកឯទ្រព្យសម្បត្តិរួម ត្រូវបែងចែកជាពីរចំណែក មួយចំណែកត្រូវប្រគល់ឱ្យសហព័ទ្ធដែលនៅរស់ និងមួយចំណែកទៀតដោយសហព័ទ្ធម្ខាងទៀតទទួលមរណភាព ដូច្នេះត្រូវធ្វើតាមសន្តតិកម្មទៅឱ្យកូនៗ ឬញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព ដោយការធ្វើសន្តតិកម្មនេះត្រូវតែមានភាពសុក្រឹត្យយោងទៅតាមច្បាប់បានកំណត់។

### ៣. មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មួយអាចធ្វើការមោឃ ឬលុបចោលបាននៅពេលមានករណីដូចជាភាគីសហព័ទ្ធគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយសារមានភាពភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលផ្សេងៗទៀត។[43] ដូចនេះក្នុងករណីដែលយើងរកឃើញមានការផ្ទុយពីឆន្ទៈរបស់សហព័ទ្ធណាម្នាក់ អាពាហ៍ពិពាហ៍អាចធ្វើមោឃភាព និងលុបចោលបាន។

## កថាខណ្ឌទី២ ការបែងចែកទ្រព្យសម្បត្តិសហព័ទ្ធ

នៅពេលអាពាហ៍ពិពាហ៍ត្រូវបានឈានដល់ទីបានបញ្ចប់ ប្រព័ន្ធទ្រព្យសម្បត្តិត្រូវបានធ្វើការរំលាយ ហើយការបែងចែកទ្រព្យសម្បត្តិនេះអាចធ្វើបានតាមពីរវិធីយ៉ាង គឺដោយតាមការព្រមព្រៀង និងតាមសេចក្តីសម្រេចតុលាការ។

### ១. ការបែងចែកទ្រព្យសម្បត្តិសហព័ទ្ធដោយការព្រមព្រៀង

ក្នុងករណីមានការព្រមព្រៀងពីភាគីសហព័ទ្ធទាំងសងខាងក្នុងការបែងចែកទ្រព្យសម្បត្តិនេះ គឺជាការបង្ហាញពីការយល់ស្របព្រមព្រៀងគ្នាថាភាគីណាទទួលបានប៉ុន្មាន ភាគីណាទទួលបានប៉ុន្មាន។ ហើយការយល់ព្រមនោះត្រូវតែកើតចេញឆន្ទៈសហព័ទ្ធទាំងសងខាងផ្ទាល់។ ក្រោយពីយល់ព្រមព្រៀងគ្នាហើយអស់ហើយ នោះតុលាការនិងចេញសេចក្តីសម្រេចលើការបែងចែកទ្រព្យសម្បត្តិនោះតាមបំណងរបស់សហព័ទ្ធទាំងពីរ។

---

[42] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧ មាត្រា៤១។

[43] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧ មាត្រា៩៥៨។

## ២. ការបែងចែកទ្រព្យសម្បត្តិតាមសេចក្តីសម្រេចរបស់តុលាការ

បើការធ្វើការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀងមិនដំណើរការល្អ ឬគ្មានការព្រមព្រៀងសហព័ទ្ធម្នាក់ៗត្រូវយកទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន ដែលមានមុនរៀបអាពាហ៍ពិពាហ៍និងទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមត៌កក្តី ជាអំណោយក្តី ជាអច្ច័យទានក្តី ក្នុងរយៈមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។[44] ហើយចំពោះទ្រព្យសម្បត្តិដែលមានភាពទាក់ទងគ្នា ឬមិនអាចធ្វើការបែងចែកគ្នាបាន នោះតុលាការនិងចេញមុខក្នុងការបែងចែកនេះ ហើយក្នុងដំណើរការនៃបែងចែកនោះត្រូវមាន ៤ដំណាក់កាលដូចជា៖

- ការចាត់ប្រភេទទ្រព្យសម្បត្តិ
- ការវាយតម្លៃលើទ្រព្យសម្បត្តិ
- ការបែងចែកទ្រព្យសម្បត្តិដោយឡែក
- ការបែងចែកទ្រព្យរួម។

### ២.១ ការចាត់ប្រភេទទ្រព្យសម្បត្តិ

ការចាត់ប្រភេទទ្រព្យសម្បត្តិ ដោយដំណាក់កាលនេះ គឺជាដំណាក់កាលក្នុងការញែកទ្រព្យសម្បត្តិ ថាទ្រព្យសម្បត្តិណាត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិណាខ្លះត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក។ គោលបំណងនៃការចាត់ប្រភេទទ្រព្យសម្បត្តិនេះ គឺដើម្បីធ្វើឱ្យកាន់តែមានភាពងាយស្រួលក្នុងការកំណត់ថាទ្រព្យណានិងត្រូវបែងចែក និងទ្រព្យសម្បត្តិណាមិនត្រូវបានបែងចែក។បន្ថែមពីនេះទៀតសោតភាគីសហព័ទ្ធទាំងសងខាងត្រូវមានអំណះអំណាង ភស្តុតាង និងបញ្ជីសារពើពន្ធមុខទ្រព្យសម្បត្តិ ដែលមានភាពស្របច្បាប់ដើម្បីចង្អុលបង្ហាញបញ្ជាក់ចំពោះទ្រព្យសម្បត្តិដែលចង់ដាក់ជាទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។

ការចាត់ប្រភេទទ្រព្យសម្បត្តិអាចមានដំណើរដូចតទៅ៖

**ការចាត់ប្រភេទទ្រព្យដោយឡែក** យើងអាចធ្វើការចាត់ប្រភេទទ្រព្យសម្បត្តិដោយឡែក ដោយសហព័ទ្ធមានទ្រព្យសម្បត្តិនោះមុនអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងកំឡុងពេលអាពាហ៍ពិពាហ៍។[45]

**ការចាត់ប្រភេទទ្រព្យរួម** ដោយទ្រព្យសម្បត្តិរួមតែងតែកើតឡើងក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ពីចំណូលដែលប្តី និងប្រពន្ធទទួលបាន។[46]

---

[44] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, មាត្រា៧០។

[45] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧២។

[46] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧៣។

ប៉ុន្តែដំណាក់កាលនៃការចាត់ចែងនេះ អាចនិងជួបនូវផលវិបាកមួយចំនួនដោយហេតុថាទ្រព្យដែលត្រូវចាត់ចែងនោះមានភាពប្រទាក់ក្រឡាស្មុគស្មាញ និងមានទំនាក់ទំនងនិងសហព័ទ្ធទាំងសងខាង ដែលហេតុជាការលំបាកកំណត់ថាទ្រព្យសម្បត្តិនោះជាទ្រព្យដោយឡែក ឬទ្រព្យសម្បត្តិរួម។

### ២.២ ការវាយតម្លៃទ្រព្យសម្បត្តិ

ដំណាក់កាលការវាយតម្លៃទ្រព្យសម្បត្តិនេះ គឺជាដំណាក់កាលដែលយកទ្រព្យសម្បត្តិមកធ្វើការវាយតម្លៃ និងថ្លឹងថ្លែងឱ្យមានភាពសម្បរម្យ។គោលបំណង នៃការវាយតម្លៃទ្រព្យសម្បត្តិនេះ គឺដើម្បីឱ្យភាគីសហព័ទ្ធទាំងសងខាងទទួលបាននៅចំណែកឱ្យមានភាពស្មើគ្នា និងសមទៅនិងអ្វីដែលពួកគាត់គួរទទួលបាន។

### ២.៣ ការប្រគល់ទ្រព្យសម្បត្តិដោយឡែក

ក្រោយពីដំណាក់កាលទាំងបីប្រព្រឹត្តទៅដោយរលូត និងមានការសង្កេតឃើញថាមានភាពសមស្របហើយ នោះដំណាក់បន្ទាប់គឺជាការប្រគល់ទ្រព្យដោយឡែកជូនទៅភាគីប្តីប្រពន្ធម្ខាងៗ នូវទ្រព្យដែលពួកគេនិងទទួលបាន ដោយទ្រព្យទាំងអស់នោះភាគច្រើនគឺជាទ្រព្យដែលពួកគេទទួលបានមុនអាពាហ៍ពិពាហ៍ ដូចជាទ្រព្យសម្បត្តិដែលទទួលបានដោយ ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និងអាចជាទ្រព្យផ្សេងៗទៀត។ [47]

### ២.៤ ការបែងចែកទ្រព្យសម្បត្តិរួម

ដំណាក់ចុងក្រោយនេះ គឺជាការប្រគល់ចែកទ្រព្យសម្បត្តិរួមទៅឱ្យសហព័ទ្ធនីមួយៗ ដែលសហព័ទ្ធនិងទទួលបានពីការយកទ្រព្យសម្បត្តិដែលពួកគេរកបានពីចំណូលក្នុងកំឡុងអាពាហ៍ពិពាហ៍មកធ្វើការបែងចែក។ សហព័ទ្ធទាំងពីរមានសិទ្ធិទទួលយក ១ភាគ ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែក្នុងការបែងចែងទ្រព្យរួមនោះ ក៏មានករណីពិសេស ដោយសហព័ទ្ធណាម្ខាងអាចធ្វើការទាមទារទៅតុលាកាក្នុងការបែងចែកទ្រព្យសម្បត្តរួម ដោយពិចារណាទៅលើករណីស្ថានភាពពិសេសផ្សេងៗដូចជា ទំហំនៃការបរិច្ចាករបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬបង្កើតទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពនៅក្នុងពេលមានចំនងអាពាហ៍ពិពាហ៍អាយុស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍។ [48]គួរបញ្ជាក់ដែលថាការបែងចែកទ្រព្យសម្បត្តិរួមនេះ អាចប្រព្រឹត្តទៅបាន ដោយមានការព្រមព្រៀងក្នុងការទទួលចំណែករាល់ទ្រព្យសម្បត្តិនេះ ពីសហព័ទ្ធ។ ក្នុងករណីដែលភាគីសហព័ទ្ធណាមួយជំទាស់ក្នុងការបែងចែកទ្រព្យសម្បត្តិនេះ នោះនិងធ្វើការជូនសមត្ថកិច្ចឱ្យតុលាការក្នុងការចាត់ចែងទ្រព្យសម្បត្តិនោះជូនដល់សហព័ទ្ធវិញ។

---

[47] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៧២។

[48] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជា២០០៧ លេខ នស/រកម/១២០៧/០៣០, មាត្រា៩៨០។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះរួចមក ឃើញថាប្រព័ន្ធទ្រព្យសម្បត្តិពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រជាពលរដ្ឋខ្មែរជាពិសេសប្តីប្រពន្ធឬសហព័ទ្ធ ដែលមានចំណងអាពាហ៍ពិពាហ៍ ដើម្បីឱ្យគាត់មានការយល់ដឹងកាន់តែច្បាស់អំពីភាពចាំបាច់ គោលបំណង និងផលប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ជាពិសេសបង្ការការទប់ស្កាត់នូវជម្លោះរវាងប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍។ ជីវិតគូរមែងមានបញ្ហា និងជម្លោះកើតឡើងដែលអាចឈានដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ហើយក្រោយការបញ្ចប់ចំណងអាពាហ៍ពិពាហ៍រវាងគ្នា មិនមែនបញ្ចប់គ្រប់យ៉ាងនោះទេ គឺស្ថិតនៅក្នុងដំណាក់ស្មុគស្មាញមួយទៀតដែលជាដំណាក់បែងចែកទ្រព្យសម្បត្តិដែលប្រជាពលរដ្ឋខ្មែរភាគច្រើនមានការធ្វេសប្រហែស ដោយសារតែកត្តានេះហើយទើបច្បាប់ក្រមរដ្ឋប្បវេណី ក៏ដូចជានៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានកំណត់យ៉ាងច្បាស់លាស់ អំពីប្រភេទទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានមានដូចជាទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម ដើម្បីជាភាពងាយស្រួលសម្រាប់សហព័ទ្ធក្នុងការកំណត់ជាក់លាក់ច្បាស់លាស់នៃទ្រព្យសម្បត្តិដោយពុំមានការឈ្លោះទាស់ទែងគ្នា នៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ។

ដើម្បីជៀសវាងទៅលើកត្តា បញ្ហាផ្សេងដែលកើតមានឡើងក្រោយការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធនីមួយៗ មានសិទ្ធិសេរីភាពក្នុងការកំណត់នូវទ្រព្យសម្បត្តិដែលខ្លួនចង់ដាក់នៅក្នុងកម្មវត្ថុតាមការព្រមព្រៀងលើកិច្ចសន្យាទ្រព្យសម្បត្តិ ឬតាមការកំណត់របស់ច្បាប់។ ចំពោះការកំណត់ទាំង២នេះមានលក្ខណៈខុសគ្នាត្រង់ថា បើសិនជាសហព័ទ្ធយល់ព្រមក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នោះពួកគាត់តម្រូវឱ្យមានការព្រមព្រៀងបង្កើតកិច្ចសន្យានោះ និងត្រូវមានការចុះបញ្ជីយ៉ាងត្រឹមត្រូវស្របតាមនីតិវិធីនៃក្រសួងយុត្តិធម៌ តែបើភាគីទាំងសងខាងយល់ថា កិច្ចសន្យាទ្រព្យសម្បត្តិនេះមិនចាំបាច់បង្កើតសម្រាប់ពួកគាត់នោះ គាត់មានសិទ្ធិក្នុងការកំណត់តាមច្បាប់ នឹងចូលខ្លួនក្នុងការអនុវត្ត។ ក្នុងការកំណត់ទាំង២នេះផងដែរគឺជួយដល់សហព័ទ្ធក្នុងការបែងចែកទ្រព្យសម្បត្តិដែលខ្លួនទទួលបានមុនអាពាហ៍ពិពាហ៍ ក៏ដូចជាក្រោយអាពាហ៍ពិពាហ៍ផងដែរដើម្បីញ៉ាំងឱ្យសម្រួលទៅលើនីតិវិធីតុលាការផងដែរ។

# អនុសាសន៍

# អនុសាសន៍

នាពេលបច្ចុប្បន្ន ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ពិតជាមានអត្ថប្រយោជន៍ហើយក៏ត្រូវបានអនុញ្ញាតឱ្យធ្វើការចុះបញ្ជីបាន ប៉ុន្តែយើងនូវតែសង្កេតថា ប្រជាពលរដ្ឋ ឬប្តីប្រពន្ធនូវតែមានបញ្ហា វិវាទកើតពាក់ព័ន្ធជាមួយនិងប្រព័ន្ធទ្រព្យសម្បត្តិនេះដដែលៗ។ ហើយនេះអាចបង្ហាញថា ការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរអំពីសារៈសំខាន់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនេះនៅមានកម្រិតនៅឡើយ លើសពីនេះទៀតចំណែកឯការផ្សព្វផ្សាយខាងវិស័យច្បាប់នៅកម្ពុជាក៏នៅពុំទាន់មានភាពលក្ខណៈទូលំទូលាយផងដែរ។ ដូច្នេះដើម្បីឱ្យមានការឈ្វេងយល់ពីសារៈសំខាន់នៃកិច្ចសន្យាទ្រព្យសម្បត្តិនេះ បុគ្គល ឬស្ថាប័នដែលពាក់ព័ន្ធ គប្បីមានការយកចិត្តទុកដាក់ និងការជំរុញទៅដល់សាធារណៈជនទូទៅឱ្យមានការអនុវត្តចំពោះការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិនេះកាន់តែកើនឡើង និងជាផ្នែកមួយក្នុងការលើកកម្ពស់ និងការអភិវឌ្ឍក្នុងវិស័យផ្នែកច្បាប់នៅកម្ពុជា។

ដោយសង្កេតឃើញមានបញ្ហាវិវាទតែងតែកើតឡើងពាក់ព័ន្ធចំពោះប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ហេតុដូច្នេះទើបយើងខ្ញុំមានជាអនុសាសន៍មួយចំនួនសម្រាប់បុគ្គលដែលពាក់ព័ន្ធគួរគប្បី៖

- យើងសូមលើកទឹកចិត្តដល់ប្តីប្រពន្ធ ឬបុគ្គលនិងត្រូវរៀបអាពាហ៍ពិពាហ៍ចូលរួមទៅចុះកិច្ចសន្យាទ្រព្យសម្បត្តិ ព្រោះការចុះកិច្ចសន្យាទ្រព្យសម្បត្តិនេះបានផ្តល់អត្ថប្រយោជន៍ដល់ពួកគាត់ជាច្រើន
- បុគ្គល ឬស្ថាប័នដែលពាក់ព័ន្ធអាចបង្កើនការផ្សព្វផ្សាយសម្រាប់វិស័យឱ្យមានភាពកាន់តែទូលាយ និងពន្យល់បកស្រាយឱ្យមានភាពងាយយល់ដល់ប្រជាពលរដ្ឋ
- បុគ្គល ឬស្ថាប័នដែលពាក់ព័ន្ធគួរតែមានការបង្កើតទម្រង់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដើម្បីផ្តល់ភាពងាយស្រួលដល់បុគ្គលទាំងឡាយណាដែលចង់ចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ
- បុគ្គល ឬដែលស្ថាប័នដេលពាក់ព័ន្ធគួរតែធ្វើការប្រមូលផ្តុំបច្ចុប្បន្នភាព និងពង្រីកវិធានផែនការកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់ ជាពិសេសទាក់ទងនិងការធ្វើចំណាត់ទ្រព្យសម្បត្តិសហាព័ទ្ធ

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរដែលជានិស្សិតជំនាញផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសន្យាថានឹងចែករំលែកនូវចំណេះដឹងទាំងឡាយណាដែលពួកខ្ញុំទទួលបានចែកជូនសិស្សប្អូន ក៏ដូចជាប្រជាពលរដ្ឋខ្មែរដើម្បីយល់ដឹង ក៏ដូចជាទីប្រឹក្សា ឬអ្នកផ្តល់ជាគំនិតយោបល់ ជូនពួកគាត់ដែលពុំទាន់យល់ដឹងពត៌មានដែលទាក់ទងច្បាប់ ដើម្បីឱ្យពួកគាត់កាន់តែយល់ច្បាស់ និងដោះស្រាយគ្រប់បញ្ហាទាំងឡាយណាដែលកើតមានឡើង យ៉ាងសមប្រកប នឹងត្រឹមត្រូវបានផ្លូវច្បាប់។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើនៅថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងអនុវត្តទូទាំងប្រទេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

៣. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

៤. ប្រកាសស្តីពីនីតិវិធីណែការចុះបញ្ជីកិច្ចសន្យទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣

## ២. សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗ

១. សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ឆ្នាំ ២០១០

២. គេហទំព័រ NOLO Law Firm ស្តីពីទ្រព្យសម្បត្តិដាច់ដោយឡែក និងអាពាហ៍ពិពាហ៍ ឆ្នាំ២០២

៣. លោកហ៊ីង គីមឡេង និង លោក ឆឹង ស៊ីនៀង , សិក្ខាសាលាស្តីពី "ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ" , ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០១៦

៤. "កម្រងមេរៀន" រៀបរៀងដោយវិភាគទានច្បាប់, បោះពុម្ភឆ្នាំ ២០១៧,ទំព័រសរុប៥៦៧

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# នីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈកិច្ចសន្យា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១
ប្រកាស ១៩

## ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ......................ភេទ ប្រុស អាយុ.................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ......................ភេទ ស្រី អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

### សូមគោរពជូន
### ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:..................(ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)...... ។
- មូលហេតុ:....................(កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)......... ។
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ:.......(សរសេរខ្លឹមសារកិច្ចសន្យាទាំងអស់).........
.......................................................................................................................
.......................................................................................................................
......................................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

p ស្នាមម្រាមដៃ

ប្តីឈ្មោះ ប្រពន្ធឈ្មោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី ២ |
|---|
| ប្រការ ២០ |

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ......................ភេទ ប្រុស អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ...............រាជធានី ខេត្ត........... ។

ឈ្មោះ......................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង........................ភេទ......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ.........(ចុះបញ្ជីផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)...... ។
- មូលហេតុៈ...........(ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្តូរៈ.......(សរសេរទាំងអស់នូវខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រោយពីការផ្លាស់ប្តូររួច)........................................................................................................................................................................................................................................................................................................................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ៣
ប្រការ ២០

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន

ឈ្មោះ.......................ភេទ ....... អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ឬ ប្រពន្ធ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន។

- គោលបំណងនៃការចុះបញ្ជី:....................(ចុះបញ្ជីផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន)...... ។
- មូលហេតុ:......................(ការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្តូរ:.......(ឈ្មោះថ្មី ឬ អាសយដ្ឋានថ្មី)..........................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ឈ្មោះ**

p

| ឧបសម្ព័ន្ធទី ៤<br>ប្រការ ២១ |
|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ........................គោត្ត ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះ........................គោត្ត ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង........................គោត្ត.......អាយុ........ថ្ងៃខែឆ្នាំកំណើត............. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការការកែតម្រូវការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ...........(កែតម្រូវកំហុស ឬ ការខកខានមិនបានចុះបញ្ជី).... ។
- មូលហេតុៈ......................(មានកំហុស ឬ ការខកខានមិនបានចុះបញ្ជី).................... ។
- ចំណុចដែលត្រូវកែតម្រូវៈ
  - ឈ្មោះ......................................................................................................
  - អាសយដ្ឋាន...............................................................................................
  - ថ្ងៃខែឆ្នាំកំណើត...........................................................................................
  - ខ្លឹមសារនៃទ្រព្យសម្បត្តិប្តីប្រពន្ធ...........................................................................

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| ឧបសម្ព័ន្ធទី ៥ |
| ប្រការ ២២ - ២៧ |

# ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ [1]

ឈ្មោះ.........................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ.........................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ...........(លុបការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ)................ ។
- មូលហេតុៈ......................(ការរំលាយអាពាហ៍ពិពាហ៍ ព្រមទាំងកាលបរិច្ឆេទ ឬ រំលាយកំជាប់ពាក្យ ព្រមទាំងកាលបរិច្ឆេទ).........................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០........

**ស្នាមម្រាមដៃ**

p

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

---

[1] ក្នុងករណីមោឃភាព ការលុបចោល ឬការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ រំលាយអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ ដោយផ្អែកលើសេចក្តីសម្រេចរបស់តុលាការ អ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំតែម្នាក់ឯងបាន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៦
ប្រការ ២៨

## ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឈ្មោះ......................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់.............ក្រុង ស្រុក ខណ្ឌ...............រាជធានី ខេត្ត........... ។

ឈ្មោះ......................ភេទ ស្រី អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់.............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.......................ភេទ......អាយុ.......ថ្ងៃខែឆ្នាំកំណើត.............. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត.................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

- គោលបំណងនៃការចុះបញ្ជី ៖ ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ។
- មូលហេតុៈ ការរៀបអាពាហ៍ពិពាហ៍ ។
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ៖........................................................ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៧
ប្រការ ៤៨

## ពាក្យសុំឲ្យចេញលិខិតបញ្ជាក់

ឈ្មោះ......................ភេទ ....... អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ឬ ប្រពន្ធ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ ជាបុគ្គលផ្សេងទៀត អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ.............ភូមិ.............. ឃុំ សង្កាត់.................. ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.......................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

### សូមគោរពជូន
### ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំឲ្យចេញលិខិតបញ្ជាក់។

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ចំណុចដែលត្រូវធ្វើការបញ្ជាក់ ៖ ...........................
- ចំនួនលិខិតបញ្ជាក់ ៖......................ច្បាប់

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.. .....

ស្នាមម្រាមដៃ

ឈ្មោះ

p

# សន្លឹកក្រដាសទទួលពាក្យសុំ

| លេខរៀង ទទួលពាក្យ | កាលបរិច្ឆេទនៃ ការទទួលពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាង (ប្រសិនបើមាន) | ប្រភេទ នៃការចុះបញ្ជីកិច្ចសន្យា ប្តីប្រពន្ធ | ជាប្តីប្រពន្ធ | ជាបុគ្គលដែលត្រូវ រៀបការជាមួយគ្នា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៩

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ ថ្ងៃទី......ខែ..........ឆ្នាំ..........

| លេខចុះបញ្ជី[2] : | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : <br> ថ្ងៃខែឆ្នាំកំណើត : <br> អាសយដ្ឋាន : | | | | |
| ឈ្មោះ : <br> ថ្ងៃខែឆ្នាំកំណើត : <br> អាសយដ្ឋាន : | | | | |

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

គោលបំណងនៃការចុះបញ្ជី :
មូលហេតុ និងកាលបរិច្ឆេទ :

ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :

[2] លេខចុះបញ្ជី ៖ សំដៅទៅលើលេខដែលបានចុះនៅក្នុងសន្លឹកក្រដាសទទួលពាក្យសុំ (ឧបសម្ព័ន្ធទី ៨) ត្រង់ខ្ទង់ "ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ" ។

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១០

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី.........ខែ... ... ...ឆ្នាំ..........

| លេខចុះបញ្ជី [3] | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖ | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖ |
|---|---|---|
| | | |

គោលបំណងនៃការចុះបញ្ជី :

មូលហេតុ និងកាលបរិច្ឆេទ :

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

p

[3] លេខចុះបញ្ជី ៖ សំដៅទៅលើលេខដែលបានចុះនៅក្នុងសន្លឹកក្រដាសទទួលពាក្យសុំ ( ឧបសម្ព័ន្ធទី ៨ ) ត្រង់ខ្ទង់ "ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ" ។

គំរូចុះបញ្ជី ១
ការទទួលពាក្យសុំ

# សន្លឹកក្រដាសទទួលពាក្យសុំ

| លេខរៀងទទួលពាក្យ | កាលបរិច្ឆេទនៃការទទួលពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាង (ប្រសិនបើមាន) | ប្រភេទនៃការចុះបញ្ជីកិច្ចសន្យា ប្ដីប្រពន្ធ | ជាប្ដីប្រពន្ធ | ជាបុគ្គលដែលត្រូវរៀបការជាមួយគ្នា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ០១ | ២០.០៣.២០១៣ | - ហុក ច័ន្ទសុវណ្ណារ៉ា #១៨២B, St. ៩ ...... - លី សាមឌី #១៨៣A, St. ៩ ...... ① | | កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | -ប្ដី -ប្រពន្ធ | | |
| ០២ | d | - ហុក ច័ន្ទសុវណ្ណារ៉ា #១៨២B, St. ៩ ...... - លី សាមឌី #១៨៣A, St. ៩ ... .. ① | | ផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | | | |
| ០៣ | | ធីរៈ ② | | | | | |
| ០៤ | | យស ③ | | | | | |
| ០៥ | | រតនា ④ | | | | | |
| ០៦ | | ឫទ្ធី ⑤ | | | | | |
| ០៧ | | Emiko ⑥ | | | | | |
| ០៨ | | ធីរៈ ② | | លុបកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ២ ការបង្កើត |
|---|

ឪស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

## សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ . .. | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ .... | | | | |

| | | |
|---|---|---|
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : បង្កើត<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣ | ហត្ថលេខាបំព្រួញ |

### ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងភាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

p

ហត្ថលេខា
រដ្ឋមន្ត្រី

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :

[illegible]
[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៣
ការបង្កើត

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៥.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. 6 ...... | | | | |
| ឈ្មោះ : លី សាមនី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. 6 ...... | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |
|---|---|---|

គោលបំណងនៃការចុះបញ្ជី : បង្កើត

មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាបំព្រួញ)

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខរៀងទទួលពាក្យសុំ ៖ ០១
លេខរៀងចុះបញ្ជី ៖ ០១

# កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ប្ដីឈ្មោះ ហុក ច័ន្ទសុវណ្ណារ៉ា ភេទ ប្រុស សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ប្រពន្ធឈ្មោះ លី សាមឌី ភេទ ស្រី សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ក្នុងនាមជាប្ដីប្រពន្ធ យើងបានព្រមព្រៀងគ្នាទៅលើទ្រព្យសម្បត្តិរបស់ភាគីទាំងសងខាង ដូចខាងក្រោម ៖
១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្ដី។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)
២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥
៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្ដី។
Lexus 570
ផ្លាកលេខ ៖ 2A 8844
៤. ទាក់ទងកាតព្វកិច្ចដែលប្ដីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។
៥. ទ្រព្យសម្បត្តិដែលប្ដី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៣

ស្នាមម្រាមដៃ ស្នាមម្រាមដៃ

ឈ្មោះប្ដី ឈ្មោះប្រពន្ធ
ហុក ច័ន្ទសុវណ្ណារ៉ា លី សាមឌី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៤
ការផ្លាស់ប្តូរកិច្ចសន្យា

ពីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣

| | | |
|---|---|---|
| លេខចុះបញ្ជី : ០១ | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖<br>ហុក ច័ន្ទសុវណ្ណារ៉ា | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖<br>លី សាមឌី |

គោលបំណងនៃការចុះបញ្ជី : ការផ្លាស់ប្តូរ

ហត្ថលេខាបំព្រួញ

មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១ ០៤ ២០១៣

## ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងកាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

ហត្ថលេខា
រដ្ឋមន្ត្រី

p

ក្រសួងការពារសុខសាធារណៈនិងកិច្ចការប្រជុំជន (ក្រសួងការអភិវឌ្ឍន៍) – [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៥
ការផ្លាស់ប្តូរកិច្ចសន្យា

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖<br>ហុក ចន្ទសុវណ្ណារ៉ា | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖<br>លី សាមឌី |
|---|---|---|

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : ការផ្លាស់ប្តូរ<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០៤.២០១៣ | ហត្ថលេខាបំព្រួញ |

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

ហត្ថលេខា
រដ្ឋមន្ត្រី

p

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខរៀងទទួលពាក្យសុំ ៖ ០២
លេខរៀងចុះបញ្ជី ៖ ០១

# កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីឈ្មោះ ហុក ច័ន្ទសុវណ្ណារ៉ា ភេទ ប្រុស សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ប្រពន្ធឈ្មោះ លី សាមនី ភេទ ស្រី សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ក្នុងនាមជាប្តីប្រពន្ធ យើងបានព្រមព្រៀងគ្នាធ្វើការផ្លាស់ប្តូរទៅលើទ្រព្យសម្បត្តិចំនួន ២ ក្នុង ចំនោមទ្រព្យសម្បត្តិដែលបានព្រមព្រៀងពីមុន ដូចខាងក្រោម ៖

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៣

| | |
|---|---|
| ស្នាមម្រាមដៃ | ស្នាមម្រាមដៃ |
| p | |
| ឈ្មោះប្តី | ឈ្មោះប្រពន្ធ |
| ហុក ច័ន្ទសុវណ្ណារ៉ា | លី សាមនី |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៦
ការលុបការចុះបញ្ជី

និស្ស័ការគ្រួសារយុត្តិធម៌
នាយកដ្ឋានកិច្ចការជ្រើរើសរើស

## សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ ...... | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ ... . | | | | |

| | |
|---|---|
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ |

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាបំព្រួញ)

### ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងកាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥ ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :

លុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើដីកាសម្រេចលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង លេខ ០១ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២០

(ហត្ថលេខាបំព្រួញ)

(ហត្ថលេខា រដ្ឋមន្ត្រី)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

| គំរូចុះបញ្ជី ៧ |
| --- |
| ការលុបការចុះបញ្ជី |

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
| --- | --- | --- | --- | --- |
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៤២B, St. ៩ ...... | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥ ១០.១៩៨១<br>អាសយដ្ឋាន : #១៤៣A, St. ៩ ..... | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |
| --- | --- | --- |

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាប់ព្រួញ)

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :
លុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើដីកាសម្រេចលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង លេខ ០១
ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០២០ (ហត្ថលេខាប់ព្រួញ)

(ហត្ថលេខា រដ្ឋមន្ត្រី)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ៨ |
| --- |
| ការផ្លាស់ប្ដូរអាសយដ្ឋាន |

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៥

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
| --- | --- | --- | --- | --- |
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : ផ្ទះលេខ ១៨២B, ផ្លូវលេខ ៩ សង្កាត់ មានជ័យខណ្ឌមានជ័យ រាជធានីភ្នំពេញ. | ផ្ទះលេខ ៣០E០ ផ្លូវ ១៦៣ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ | ផ្លាស់ប្ដូរអាសយដ្ឋាន | ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៥ | ហត្ថលេខា |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : ផ្ទះលេខ ១៨៣A, ផ្លូវលេខ ៩ សង្កាត់ មានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ |
| --- | --- |

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះថ្ងៃទី ០១ ០១.២០១៣

ហត្ថលេខាបំពេញ

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្ដី។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាលសិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)
២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបសប្រពន្ធ។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥
៣ រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្ដី។
Lexus 570
ផ្លាកលេខ ៖ 2A 8844
៤. ទាក់ទងកាតព្វកិច្ចដែលប្ដីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។
៥. ទ្រព្យសម្បត្តិដែលប្ដី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។
p

ហត្ថលេខា
រដ្ឋមន្ត្រី

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :

# ឧបសម្ព័ន្ធទី២

# សាលក្រមសាលាដំបូងរាជធានីភ្នំពេញសំណុំរឿងរដ្ឋប្បវេណី
# លេខ១៦៩៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

**សំណុំរឿងរដ្ឋប្បវេណី**

លេខ ១៦៩៥

ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

**សាលក្រមលេខ ៥០៣ "ម"**

ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២១

បានបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ នៅសាលសវនាការទី ៥។

**ចៅក្រមជំនុំជម្រះ**

លោក **ភួយ សៅ** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីជំនុំជម្រះ**

លោកស្រី **នុយ អន្ធារ៉ាក** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ៖**

ឈ្មោះ ម៉ែន កានី ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១០១៨០៨២ មុខរបរ អ្នករកស៊ី អាសយដ្ឋានបច្ចុប្បន្នផ្ទះគ្មានលេខ ផ្លូវលំ ភូមិថ្នល់បន្ទាយ សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ៖**

លោកមេធាវី អ៊ី ចំរើន អត្តលេខ ៨១០ អាសយដ្ឋានបច្ចុប្បន្នផ្សារស៊ីធីម៉ល ជាន់ទី៣ ផ្លូវ២៧១ សង្កាត់វាលវង្ស ខណ្ឌ៧មករា រាជធានីភ្នំពេញ។

លោកមេធាវី ស្ន សុវណ្ណារិទ្ធិ អត្តលេខ ២១៣៧T អាសយដ្ឋានបច្ចុប្បន្នផ្សារស៊ីធីម៉ល ជាន់ទី៣ ផ្លូវ២៧១ សង្កាត់វាលវង្ស ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ចុងចម្លើយ៖**

ឈ្មោះ យ៉ាន់ គីមហួច ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ មេផ្ទះ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១១ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ៖**

លោកមេធាវី ហ៊ិន វុទ្ធី អត្តលេខ ២០៣៨ ជាសមាជិកនៃក្រុមមេធាវីធម្មសាស្ត្រ មានការិយាល័យស្ថិតនៅជាន់ទី ១០ បន្ទប់លេខ P10-11 នៃអាគារសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU) ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## ១.អង្គហេតុ និង ចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១. ឱ្យដើមចោទលែងលះពីចុងចម្លើយ។

២. ផ្ដល់អំណាចមេបាលើកូនទាំង៤នាក់ឱ្យទៅដើមចោទ

- ទី១ ឈ្មោះ កានី សាស្ដា ភេទប្រុស កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦។
- ទី២ ឈ្មោះ កានី វីរៈបុត្រ ភេទប្រុស កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥។
- ទី៣ ឈ្មោះ កានី វីរៈយុទ្ធ ភេទប្រុស កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨។
- ទី៤ ឈ្មោះ កានី ដេលីឡា ភេទស្រី កើតថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២០

៣.បែងចែកទ្រព្យសម្បត្តិរួមគ្នាមាន ៖

៣.១.ប្រគល់ ដី និងផ្ទះមួយកន្លែង មានទីតាំងស្ថិតនៅផ្លូវលំ ក្រុម១១ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឱ្យទៅកូនៗទាំង៤នាក់។

៣.២.ប្រគល់រថយន្តមួយគ្រឿងម៉ាក AUDI Q7 ស៊េរីឆ្នាំ២០១២ ពាក់ស្លាកលេខ ភ្នំពេញ 2AM-1771 និង គ្រឿងអលង្ការឱ្យចុងចម្លើយ។

### ខ. ដំណើររឿងក្ដី និងចំណុចវិវាទ ៖

ខ.១. ការសង្ខេបអំពីរឿងក្ដី ៖

នៅក្នុងរឿងក្ដីនេះ ដើមចោទ និងចុងចម្លើយបានរៀបការដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៤០ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានខណ្ឌ៧មករា។ ក្នុងចំណងអាពាហ៍ពិពាហ៍នេះដើមចោទ និងចុងចម្លើយ មានកូនចំនួន៤នាក់។ កូនទី១ ឈ្មោះ កានី សាស្ដា ភេទប្រុស អាយុ១៤ឆ្នាំ កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ កូនទី២ ឈ្មោះ កានី វីរៈបុត្រ ភេទប្រុស អាយុ៥ឆ្នាំ កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ កូនទី៣ ឈ្មោះ កានី វីរៈយុទ្ធ ភេទប្រុស អាយុ២ឆ្នាំ កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ និងកូនទី៤ ឈ្មោះ កានី ដេលីឡា ភេទស្រី អាយុ១ខែ កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០។ មួយរយៈមកនេះ ការរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយពុំមានការចុះសម្រុងនឹងគ្នាឡើយ។ រហូតមកដល់ពេលនេះ ដើមចោទ និងចុងចម្លើយ អស់មនោសញ្ចេតនានឹងគ្នាជាប្ដីប្រពន្ធទៀតហើយ។ ហេតុនេះហើយ បានជាដើមចោទប្ដឹងសុំលែងលះពីចុងចម្លើយមកតុលាការដោយសុំឱ្យតុលាការចេញសាលក្រមសម្រេចឱ្យដើមចោទលែងលះពីចុងចម្លើយ ប្រគល់អំណាចមេបាលើកូនទាំង៤នាក់ឱ្យទៅដើមចោទ និងសុំឱ្យបែងចែកទ្រព្យសម្បត្តិរួម។

ខ.២ អង្គហេតុដែលមានវិវាទ ៖

តើដើមចោទ និងចុងចម្លើយ ពិតជាមានមូលហេតុលែងលះដែររឺទេ?

ខ.៣ អង្គហេតុដែលគ្មានវិវាទ ៖

ខ.៣.១ ដើមចោទព្រមឱ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនទាំង៤នាក់។

### ខ.៤ ការអះអាងរបស់ភាគី

ខ.៤.១. ការអះអាងរបស់ដើមចោទ៖

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានធ្វើសេចក្ដីអះអាងដូចខាងក្រោម ៖

១. ខ្ញុំបាទឈ្មោះ ម៉ែន កានី សុំលែងលះពីប្រពន្ធឈ្មោះ យ៉ាន់ គីមហួច អាយុ៣៧ឆ្នាំ។

២. សុំអំណាចមេបាលើកូនចំនួន៤នាក់៖ ទី១.ឈ្មោះ កានី សាស្តា ភេទប្រុស កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦, កូនទី២.ឈ្មោះ កានី វីរៈបុត្រ ភេទប្រុស កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥, ទី៣.ឈ្មោះ កានី វីរៈយុទ្ធ ភេទប្រុស កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ កូនទី៤. ឈ្មោះ កានី ឆេលីឡា ភេទស្រី កើតថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២០ (ករណីតុលាការ ផ្តល់សិទ្ធិអំណាចមេបាដល់ចុងចម្លើយ ខ្ញុំបាទសុខចិត្តផ្តល់អាហារកិច្ចចិញ្ចឹមកូនរហូតដល់មាននីតិភាព)។

៣. សុំប្រគល់រថយន្តមួយគ្រឿងម៉ាក AUDI Q7 ស៊េរីឆ្នាំ២០១២ ពាក់ស្លាកលេខ ភ្នំពេញ 2AM-1771 និង គ្រឿងអលង្ការឱ្យចុងចម្លើយ។ ប្រគល់ដីនិងផ្ទះមួយកន្លែង មានទីតាំងស្ថិតនៅផ្លូវលំ ក្រុម១១ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឱ្យទៅកូនៗទាំង៤នាក់។

ខ្ញុំបាទសូមជម្រាបថា កាលពីអំឡុងឆ្នាំ២០០៧ ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ យ៉ាន់ គីមហួច និង បាន ទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៤០ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានខណ្ឌ៧មករា តាមច្បាប់។ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាមក ខ្ញុំបាទ និងចុងចម្លើយ មានកូនចំនួន៤នាក់៖ កូនទី១ ឈ្មោះ កានី សាស្តា ភេទប្រុស អាយុ១៤ឆ្នាំ កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ១៥៩ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៨ កូនទី២ឈ្មោះ កានី វីរៈបុត្រ ភេទប្រុស អាយុ៥ឆ្នាំ កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ២៨៥ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ទី៣ឈ្មោះ កានី វីរៈយុទ្ធ ភេទប្រុស អាយុ២ឆ្នាំ កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣៨៥ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ និងកូនទី៤ ឈ្មោះ កានី ឆេលីឡា ភេទស្រី អាយុ១ខែ កើតថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២០ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៥០១ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០។

ចំពោះកូនទាំង៤នាក់ ខ្ញុំបាទសុំផ្តល់សោហ៊ុយសម្រាប់បង់ថ្លៃសិក្សាឱ្យកូនៗទាំង៤នាក់លើការរៀនសូត្រ និងផ្តល់សោហ៊ុយចិញ្ចឹមបីបាច់ថែរក្សាកូនទាំង៤នាក់ ក្នុងមួយខែៗចំនួន ៤០០០ (បួនពាន់) ដុល្លារអាមេរិក។ ខ្ញុំបាទ ស្នើសុំចូលជួបប្រាស្រ័យទាក់ទង សួរសុខទុក្ខជាមួយកូនៗ ពេលណាដែលខ្ញុំទំនេរពីការងារ។ ខ្ញុំបាទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមគ្នាមាន៖ ដី និងផ្ទះមួយកន្លែង មានទីតាំងស្ថិតនៅផ្លូវលំ ក្រុម១១ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលចុងចម្លើយកំពុងរស់នៅគឺខ្ញុំប្រគល់ឱ្យកូនៗទាំង៤នាក់ និងរថយន្តមួយគ្រឿងម៉ាក AUDI Q7 ស៊េរីឆ្នាំ២០១២ ពាក់ស្លាកលេខ ភ្នំពេញ 2AM-1771 និងគ្រឿងអលង្ការ ដែលចុងចម្លើយកំពុងតែប្រើប្រាស់រាល់ថ្ងៃ ខ្ញុំប្រគល់ឱ្យចុងចម្លើយ។

ក្នុងអំឡុងពេលដែលខ្ញុំបាទរួមរស់នៅមួយគ្នា យើងទាំងពីរនាក់តែងតែឈ្លោះប្រកែកគ្នាជាញឹកញាប់ រហូតដល់មានកូនទី៣ជម្លោះក្នុងគ្រួសារកាន់តែច្រើនឡើងៗរហូតដល់ខ្ញុំបាទសម្រេចចិត្តចាកចេញមករស់នៅខាងក្រៅផ្ទះបណ្តោះអាសន្នដើម្បីកាត់បន្ថយការឈ្លោះប្រកែកគ្នា និងខ្លាចកើតមានអំពើហិង្សាក្នុងគ្រួសារ។ ប៉ុន្តែ ទោះបីខ្ញុំបាទខំប្រឹងទប់ និងបញ្ចៀសយ៉ាងណាក៏ចុងចម្លើយនៅតែតាមមករករឿងផ្ញើរសារ និងបង្ហោះសារ គ្រប់បែបយ៉ាងដើម្បីបង្ខូចកិត្តិយសខ្ញុំបាទមិនចេះចប់មិនចេះហើយ ទើបធ្វើឱ្យខ្ញុំបាទអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាបន្តទៀតបាននោះទេ។

ចំពោះខ្ញុំនៅតែចង់លែងលះជាមួយប្រពន្ធខ្ញុំដដែល ព្រោះថាតាមពិតយើងទាំងពីរនាក់មុនឈានចូលមកដល់ការប្តឹងលែងលះគ្នានៅតុលាការនេះ ខ្ញុំក៏ធ្លាប់បានធ្វើការផ្សះផ្សារគ្នានៅសង្កាត់ម្តងរួចហើយតាំងតែពីកូនទីមួយម្ល៉េះ។ ខ្ញុំទាំងពីរនាក់មានគំនិត និងយោបល់ផ្ទុយគ្នារហូត ជាហេតុមិនអាចអោយខ្ញុំបន្តការរស់ជាប្តីប្រពន្ធបន្តទៀតនោះទេ។

**ខ.៤.២. ការអះអាងរបស់ចុងចម្លើយ ៖**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយបានធ្វើសេចក្តីអះអាងដូចខាងក្រោម ៖

នាងខ្ញុំ មិនយល់ព្រមលែងលះជាមួយប្តីនោះទេ។ នាងខ្ញុំ នៅតែស្រលាញ់ប្តី ខ្ញុំស្រលាញ់ប្តីខ្ញុំខ្លាំងណាស់ ហើយម្យ៉ាងខ្ញុំមានកូនជាមួយគាត់ដល់ទៅ៤នាក់ហើយ នាងខ្ញុំសុំសិទ្ធិអំណាចមេបាលើកូនទាំង៤នាក់នេះ។ ចំពោះការអះអាងរបស់ដើមចោទខ្ញុំទទួលស្គាល់ថាជាការពិត នាងខ្ញុំ សុំកែប្រែកំហុសទាំងអស់ឡើងវិញ សុំឱ្យតែដើមចោទត្រឡប់មករស់នៅក្នុងផ្ទះវិញ។ ខ្ញុំ និងដើមចោទ មានកូនជាមួយគ្នាចំនួន៤នាក់ ដូចការអះអាងរបស់ដើមចោទពិតមែន។ ខ្ញុំមិនឯកភាពប្រគល់អំណាចមេបាលើកូនឱ្យទៅដើមចោទទេ មូលហេតុមិនឱ្យកូនទៅប្តីដោយសារតែខ្ញុំមិនព្រមលែងលះពីប្តី។ ចំពោះទ្រព្យសម្បត្តិរួមគ្នាដែលដើមចោទបានអះអាងនោះគឺនៅមានច្រើនទៀតមិនមែនមានតែប៉ុណ្ណឹងទេ ប៉ុន្តែទ្រព្យសម្បត្តិភាគច្រើនគឺមានតែឈ្មោះគាត់តែម្នាក់ឯងទេ។

**សំអាងហេតុ**

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង ៖

១. តុលាការពិនិត្យឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់ដើមចោទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ស្របតាមបញ្ញត្តិមាត្រា ៧៥ និងមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះ តុលាការអាចលើកយកពាក្យបណ្តឹងនេះមកពិនិត្យ ពិចារណា និងចាត់ការតាមនីតិវិធីច្បាប់បានស្របតាមបញ្ញត្តិមាត្រា ៣ និងមាត្រា ៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

២. ឃើញថា ដើមចោទ និងចុងចម្លើយ ពិតជាបានរៀបមង្គលការ និងចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៤០ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានខណ្ឌ៧មករា ប្រាកដមែន ស្របទៅនឹងមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី។ តុលាការបានសាកល្បងធ្វើការផ្សះផ្សារគូភាគី ដើម្បីអាចឈានទៅដល់ការសះជានិងគ្នាឡើងវិញ ដើម្បីផលប្រយោជន៍ផ្សេងៗ នៅក្នុងគ្រួសាររបស់ពួកគេ ក៏ដូចជាផលប្រយោជន៍របស់សង្គម ជាពិសេសសម្រាប់ផ្តល់នៅភាពកក់ក្តៅដល់កូនៗរបស់ពួកគេ។ ប៉ុន្តែភាគីទាំងពីរនៅតែមិនអាចឈានដល់ការសះជានឹងគ្នាបានវិញឡើយ។ ដូច្នេះ តុលាការពិនិត្យឃើញថា ទំនាក់ទំនងនៃភាពជាប្តីប្រពន្ធ ស្របច្បាប់របស់ពួកគេត្រូវបានបែកបាក់ហើយ ដែលមិនអាចសះជានឹងគ្នាបានឡើយ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានត្រឡប់មកវិញបាននោះទេ។ ដូចនេះ តុលាការពិចារណាឱ្យភាគីលែងលះ ស្របតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៣. ឃើញថា ដើមចោទ និងចុងចម្លើយ មានកូនចំនួន ៤ (បួន) នាក់៖ កូនទី១ ឈ្មោះ កានី សាស្តា ភេទប្រុស អាយុ១៤ឆ្នាំ កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ១៥៩ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៨ កូនទី២ឈ្មោះ កានី វីរៈបុត្រ ភេទប្រុស អាយុ៥ឆ្នាំ កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ២៨៤ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ទី៣ឈ្មោះ កានី វីរៈយុទ្ធ ភេទប្រុស អាយុ២ឆ្នាំ កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ដែលមានសំបុត្របញ្ជាក់

កំណើតលេខ៣៨៥ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ កូនទី៤ ឈ្មោះ កានី ដេលីឡា ភេទស្រី អាយុ១ខែ កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៥០១ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០។

៤. ឃើញថា ដើមចោទ និងចុងចម្លើយ បានអះអាងទាមទារសិទ្ធិអំណាចមេបាលើកូនរៀងៗខ្លួន។ បន្ទាប់ពីធ្វើនីតិវិធីផ្សះផ្សាមក ដើមចោទ សុខចិត្តប្រគល់អំណាចមេបាលើកូនទាំង៤នាក់ឱ្យទៅចុងចម្លើយគ្រប់គ្រង ព្រមទាំងផ្តល់សោហ៊ុយចាំបាច់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនទាំង៤នាក់ ក្នុងមួយខែចំនួន ៤០០០ (បួនពាន់) ដុល្លារអាមេរិក និងចំណាយលើការបង់ថ្លៃសិក្សាតាមជាក់ស្តែង។

៥. ឃើញថា ចំពោះ ដី និងផ្ទះមួយកន្លែង មានទីតាំងស្ថិតនៅផ្លូវលំ ក្រុម១១ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលចុងចម្លើយកំពុងរស់នៅសព្វថ្ងៃជាមួយកូន ដើមចោទសុខចិត្តប្រគល់ឱ្យទៅកូនទាំង៤នាក់គ្រប់គ្រង ហើយចំពោះរថយន្តមួយគ្រឿងម៉ាក AUDI Q7 ស៊េរីឆ្នាំ២០១២ ពាក់ស្លាកលេខ ភ្នំពេញ 2AM-1771 និង គ្រឿងអលង្ការ ដើមចោទប្រគល់ឱ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិ។

៦. ឃើញថា តុលាការបានពិនិត្យភស្តុតាងជាឯកសាររបស់ភាគី ដូចខាងក្រោម៖

- សំបុត្រអាពាហ៍ពិពាហ៍លេខ៤០ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានខណ្ឌ៧មករា។
- សំបុត្របញ្ជាក់កំណើតលេខ ១៥៩ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៨ របស់ឈ្មោះ កានី សាស្តា។
- សំបុត្របញ្ជាក់កំណើតលេខ ២៨៤ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ របស់ឈ្មោះ កានី វិរៈបុត្រ។
- សំបុត្របញ្ជាក់កំណើតលេខ ៣៨៥ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់ឈ្មោះ កានី វិរៈយុទ្ធ។
- សំបុត្របញ្ជាក់កំណើតលេខ ៥០១ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ កានី ដេលីឡា។
- លិខិតផ្ទេរសិទ្ធិកាន់កាប់គ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៦៦៧ ល.ប ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ចេញដោយអភិបាលខណ្ឌសែនសុខ។
- អត្តសញ្ញាណប័ណ្ណលេខ ០១១០១៨០៨២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ ម៉េន កានី។
- អត្តសញ្ញាណប័ណ្ណលេខ ០១០៤៩៣៩៤៥(០១) ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ របស់ឈ្មោះ យ៉ាន់ គីមហ្វូច។

៧. ឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

## សេចក្តីសម្រេចបញ្ចប់

១. ឱ្យដើមចោទឈ្មោះ ម៉េន កានី លែងលះ ជាមួយនឹងចុងចម្លើយឈ្មោះ យ៉ាន់ គីមហ្វូច តទៅ។

២. ប្រគល់អំណាចមេបាឱ្យចុងចម្លើយ លើកូនទាំង៤នាក់ ៖

២.១. ឈ្មោះ កានី សាស្តា ភេទប្រុស កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦

២.២. ឈ្មោះ កានី វិរៈបុត្រ ភេទប្រុស កើតថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥

២.៣.ឈ្មោះ កានី វិរៈយុទ្ធ ភេទប្រុស កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨

២.៤.ឈ្មោះ កានី ដេលីឡា ភេទស្រី កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០។